ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ (Lab Protocol) សម្រាប់ការរៀន និងបង្រៀន នៅមធ្យមសិក្សាទុតិយភូមិ

# មុខវិជ្ជា ផែនដីវិទ្យា

គាំទ្រដោយគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា
សម្រាប់ការអប់រំមធ្យមសិក្សាទុតិយភូមិ STEP UP

កុម្ភៈ ២០២៥

# **បុព្វកថា**

ក្រសួងអប់រំ យុវជន និងកីឡា បានដាក់ចេញនូវវិធានការកំណែទម្រង់វិស័យអប់រំ ដោយផ្ដោតលើការពង្រឹងគុណភាពអប់រំនៅគ្រប់កម្រិតសិក្សា និងការបង្កើនការចូលរៀនមុខវិជ្ជាវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ជាពិសេសការលើកកម្ពស់ការអប់រំស្ទែម ដែលជាមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍធនធានមនុស្សសម្រាប់សង្គម និងសេដ្ឋកិច្ចកម្ពុជា នាសតវត្សរ៍ទី២១។

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងផ្ដល់ការគាំទ្រទាំងផ្នែករឹង និងផ្នែកទន់ដល់សាលារៀន ដូចជា ការធ្វើទំនើបកម្មថ្នាក់រៀន បន្ទប់ពិសោធន៍ ការបំពាក់សម្ភារៈ និងឧបករណ៍ពិសោធន៍ ការផ្ដល់ឯកសារគាំទ្រដល់ការរៀន និងបង្រៀន ការបំប៉ននិងបង្វឹកគ្រូបង្រៀន និងការលើកកម្ពស់ការសិក្សាបន្ថែមក្រៅម៉ោង។ ទន្ទឹមគ្នានេះ **សៀវភៅណែនាំពិសោធន៍វិទ្យាសាស្ត្រ និងការផលិតវីដេអូពិសោធន៍វិទ្យាសាស្ត្រ**(Lab Protocol) **សម្រាប់ការរៀន និងបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ** ត្រូវបានរៀបចំឡើងដើម្បីបន្ស៊ីទៅនឹងតម្រូវការនៃការអនុវត្តជាក់ស្ដែងលើការរៀន និងបង្រៀនពិសោធន៍ និងការអប់រំស្ទែម សម្រាប់ជួយលើកកម្ពស់គុណភាពនៃបង្រៀន និងរៀននៅមធ្យមសិក្សាទុតិយភូមិ ដោយមានការចូលរួមពីក្រុមគ្រូឧទ្ទេសវិទ្យាស្ថានជាតិអប់រំ ក្រុមការងារបច្ចេកទេសនៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា គ្រូបង្រៀនសាលារៀនជំនាន់ថ្មីនៃវិទ្យាល័យព្រះស៊ីសុវត្ថិ និងគ្រូបង្រៀនវិទ្យាល័យធនធាន ក្រោមការគាំទ្រថវិកាពីគម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំកម្រិតមធ្យមសិក្សា(STEP-UP)។ សៀវភៅណែនាំនេះ នឹងជួយគាំទ្រដល់ការអនុវត្តការពិសោធវិទ្យាសាស្ត្រលើមុខវិជ្ជារូបវិទ្យា គីមីវិទ្យា ជីវវិទ្យា និងផែនដីវិទ្យា ដែលក្នុងមួយមុខវិជ្ជាមានចំនួន១៨ពិសោធន៍ សម្រាប់ថ្នាក់ទី១០ ទី១១ និងទី១២ អមទៅដោយវីដេអូពិសោធន៍វិទ្យាសាស្ត្រ។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរចំពោះក្រុមការងារបច្ចេកទេស និងគ្រប់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានខិតខំប្រឹងប្រែង ធ្វើឱ្យសម្រេចបានជាផ្លែផ្កានូវស្នាដៃដ៏មានសារៈសំខាន់នេះទុកជាប្រយោជន៍ដល់អ្នកសិក្សានៅកម្ពុជា។

ថ្ងៃចន្ទ ៥រោច ខែមាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

សៀវភៅណែនាំពិសោធវិទ្យាសាស្ត្រផែនដី និងបរិស្ថានវិទ្យានេះជាសមិទ្ធផលថ្មីមួយទៀតដែលបាននិពន្ធ ផលិត និងចងក្រងក្រោមការជ្រោមជ្រែងពីក្រសួងអប់រំ យុវជន និងកីឡា និងគាំទ្រដោយគម្រោង វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា សម្រាប់ការអប់រំកម្រិតមធ្យមសិក្សា (STEP-UP)។

សៀវភៅពិសោធន៍នេះជាជំនួយដ៏សំខាន់បន្ថែមលើវីដេអូពិសោធន៍ សម្រាប់លោកគ្រូ អ្នកគ្រូឯកទេស ផែនដី និងបរិស្ថានវិទ្យាដែលកំពុងបង្រៀននៅតាមសាលាមធ្យមសិក្សាទុតិយភូមិនានាទូទាំងប្រទេសកម្ពុជាលើ បច្ចេកទេសដឹកនាំសិស្សធ្វើពិសោធន៍ទាំងនៅក្នុងថ្នាក់ ក្រៅថ្នាក់ និងក្នុងបន្ទប់ពិសោធន៍។ លក្ខណៈពិសេស ដែលធ្វើឱ្យសៀវភៅពិសោធន៍នេះខុសប្លែកពីសៀវភៅ ឬឯកសារពិសោធមុនៗនោះ គឺមានឧបករណ៍ Check List សម្រាប់គ្រូត្រួតពិនិត្យសកម្មភាពមុនពេលពិសោធន៍ អំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍ រួមជាមួយ នឹងសន្លឹកកិច្ចសិស្សធ្វើពិសោធន៍។

ប្រធានបទពិសោធន៍សរុបទាំង១៨នៅក្នុងសៀវភៅនេះ គឺត្រូវបានជ្រើសរើសសម្រាប់មេរៀនសំខាន់ៗ ដែលមាននៅក្នុងថ្នាក់ទី១០ ទី១១ និងទី១២ នៃសៀវភៅសិក្សាគោលផែនដីវិទ្យារបស់ក្រសួងអប់រំ យុវជន និងកីឡាទាំងអស់។ ការសម្រេចជ្រើសរើសយកប្រធានបទពិសោធទាំង១៨ ប្រធានបទនេះ គឺផ្អែកទៅលើការ ស្ទង់មតិរបស់លោកគ្រូអ្នកគ្រូដែលកំពុងបង្រៀនមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យានៅតាមវិទ្យាល័យធនធានក្នុង ខេត្តកំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ កំពត ព្រៃវែង និងស្វាយរៀង ដោយផ្អែកទៅលើសម្ភារៈដែលអាចរកបានក្នុង បន្ទប់ពិសោធន៍ តម្រូវការចាំបាច់ ភាពឆ្លើយតប និងការលំបាកនៃការធ្វើពិសោធជាក់ស្តែង។

សៀវភៅនេះត្រូវបានរៀបចំឡើងដោយក្រុមអ្នកជំនាញផ្នែកផែនដី និងបរិស្ថានវិទ្យា មកពីវិទ្យាស្ថាន ជាតិអប់រំ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា សាលា រៀនជំនាន់ថ្មី និងគ្រូនៅសាលាវិទ្យាល័យធនធាននៃខេត្តផ្សេងៗគ្នា រួមមាន កំពង់ឆ្នាំង កំពង់ស្ពឺ តាកែវ កំពត ព្រៃវែង និងស្វាយរៀង។ ភាពចម្រុះនៃក្រុមការងារនេះ ជានាបាននូវគុណភាព និងភាពគ្របដណ្តប់លើប្រធាន បទផ្សេងៗគ្នាយ៉ាងទូលំទូលាយ។

យើងខ្ញុំទាំងអស់គ្នាជាអ្នកនិពន្ធរង់ចាំទទួលនូវរាល់មតិយោបល់ និងគំនិតល្អពីសំណាក់ លោកគ្រូ អ្នក គ្រូ ដើម្បីចូលរួមចំណែកកែលម្អចំណុចខ្វះខាតទាំងឡាយដែលកើតមាននៅក្នុងសៀវភៅនេះ។

ក្រុមអ្នកនិពន្ធ

ចងក្រង និងបោះពុម្ពដោយៈ វិទ្យាស្ថានជាតិអប់រំ ខែមករា ឆ្នាំ២០២៥
**គាំទ្រថវិកាដោយៈ គម្រោងវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការអប់រំមធ្យមសិក្សា (STEP UP)**
© វិទ្យាស្ថានជាតិអប់រំ ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំ២០២៥

## គណៈកម្មការនិពន្ធ

| | | |
|---|---|---|
| ១) លោក | **នី សុពុទ្ធី** | គ្រូឧទ្ទេសផែនដីវិទ្យា វ.ជ.អ |
| ២) លោក | **ប៉ែន ចំរើន** | គ្រូឧទ្ទេសផែនដីវិទ្យា វ.ជ.អ |
| ៣) លោកស្រី | **ប៊ូ មករា** | គ្រូឧទ្ទេសផែនដីវិទ្យា វ.ជ.អ |
| ៤) លោកបណ្ឌិត | **អេង ចាន់ខឿន** | ព្រឹទ្ធបុរស មហាវិទ្យាល័យរ៉ែ និងភូគព្ភសាស្ត្រ វ.ប.ក. |
| ៥) លោកស្រី | **សៀវ ស្រីមៀន** | គ្រូឧត្តមសិក្សាមហាវិទ្យាល័យរ៉ែ និងភូគព្ភសាស្ត្រ វ.ប.ក. |
| ៦) លោកស្រី | **ត្ន សូរ្យលីនាថ** | សាស្ត្រាចារ្យដេប៉ា.ភូមិវិទ្យា ស.ភ.ម.ភ |
| ៧) លោក | **ជួន វណ្ណា** | អនុប្រធានការិ.នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា |
| ៨) លោកស្រី | **រ៉ា រំភួន** | គ្រូវិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី |
| ៩) លោកស្រី | **រឹម រ៉ានី** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យទេពប្រណម្យ |
| ១០) លោកស្រី | **ឈូក ដាវី** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១១) លោកស្រី | **ហាន សេដ្ឋា** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១២) លោកស្រី | **ឆន ឆដា** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យកំពង់ស្ពឺ |
| ១៣) កញ្ញា | **ផុន ស្រីណុម** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យ.ចបទ.ព្រះរាជសម្ភារ |
| ១៤) លោក | **អឿ វុទ្ធី** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៥) លោកស្រី | **សោម គឹមសាន** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៦) លោក | **ឌុច ភារ:** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យជាស៊ីមតាកែវ |
| ១៧) លោក | **សឿវម៉ារ៉ា** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ១៨) លោកស្រី | **ឌឹម ថាវី** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យព្រះបាទសុរាម្រឹត |
| ១៩) លោក | **កេត ភក្កដា** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២០) លោកស្រី | **វ៉ាត រ៉ាដា** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២១) លោកស្រី | **វ៉ាត ខូវ** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យព្រះអង្គឌួង |
| ២២) លោក | **ប៊ី សាផាត** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យស្វាយរៀង |
| ២៣) លោក | **ឌឹម ច្រេស** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យស្វាយរៀង |
| ២៤) លោកស្រី | **គឹម ចាន់រី** | គ្រូបង្រៀនផែនដីវិទ្យាវិទ្យាល័យស្វាយរៀង |

## គណៈកម្មការគ្រប់គ្រង

| | | |
|---|---|---|
| ១) ឯកឧត្តម | **អ៊ុម រម្យណី** | រដ្ឋលេខាធិការក្រសួង អ.យ.ក. |
| ២) ឯកឧត្តមបណ្ឌិត | **ឱី ខាំបូលី** | អនុប្រធានគ្រប់គ្រងគម្រោងSTEP UP |
| ៣) ឯកឧត្តមបណ្ឌិត | **សៀង សុវណ្ណា** | នាយកវិទ្យាស្ថានជាតិអប់រំ |
| ៤) លោក | **ឱី បុណ្ណា** | នាយករង វ.ជ.អ |
| ៥) លោកបណ្ឌិត | **នួវ វីរ៉ា** | នាយករង វ.ជ.អ |
| ៦) លោកស្រី | **ប៊ុន សុផានី** | នាយិការង វ.ជ.អ |
| ៧) លោក | **ថៃ ហេង** | នាយករងវិទ្យាស្ថានជាតិអប់រំ |

## គណៈកម្មការត្រួតពិនិត្យ និងកែលម្អ

| | | |
|---|---|---|
| ១) លោកបណ្ឌិត | **ប៊ុន គឹមចន់** | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| ២) លោក | **ម៉ៅ សារឿន** | ព្រឹទ្ធបុរសមហាវិទ្យាល័យគរុកោសល្យ វ.ជ.អ |
| ៣) លោក | **សម្បុ គឹមសាន្ត** | នាយករងវិទ្យាល័យព្រះស៊ីសុវត្ថិ-សាលារៀនជំនាន់ថ្មី |
| ៤) លោកស្រីបណ្ឌិត | **ឡឹយ សុគា** | ព្រឹទ្ធបុរសរងវិទ្យាស្ថានជាតិអប់រំ |
| ៥) លោក | **រឿន ឫទ្ធី** | អនុប្រធានការិ.នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ |
| ៦) លោកបណ្ឌិត | **អាន វ៉ូប្រាជ** | ព្រឹទ្ធបុរសរងវិទ្យាស្ថានជាតិអប់រំ |
| ៧) លោក | **ចេង ថុន** | អនុប្រធានដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |
| ៨) លោកស្រី | **ជុំ ឃុនសុជាតា** | គ្រូឧទ្ទេសអក្សរសាស្ត្រខ្មែរ វ.ជ.អ |

## គណៈកម្មការរចនា និងវាយអត្ថបទ

| | | |
|---|---|---|
| ១) លោកស្រី | **អ៊ុំ សោភ័ណ** | អនុប្រធានអង្គភាពកិច្ចការទូទៅ វ.ជ.អ |
| ២) លោក | **ប៊ុនលី ម៉ារឌី** | មន្ត្រីដេប៉ាតឺម៉ង់អប់រំនៃវិទ្យាស្ថានជាតិអប់រំ |
| ៣) លោក | **ចាន់ រ៉ាដា** | មន្ត្រីការិយាល័យគណនេយ្យ វ.ជ.អ |
| ៤) លោក | **ឃាង ប៉េងលី** | មន្ត្រីការិយាល័យរដ្ឋបាល វ.ជ.អ |
| ៥) លោក | **ម៉ូត ណារិន** | គ្រូឧទ្ទេសនៃវិទ្យាស្ថានជាតិអប់រំ |
| ៦) កញ្ញា | **កែវ កញ្ញា** | មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |
| ៧) កញ្ញា | **ទិរៈ ខេងឡា** | មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |
| ៨) កញ្ញា | **ជា សូជាតា** | មន្ត្រីស្ម័គ្រចិត្តដេប៉ាតឺម៉ង់អប់រំ វ.ជ.អ |

# មាតិកា


បុព្វកថា...................................................................................................i
អារម្ភកថា .................................................................................................. ii
គណៈកម្មការនិពន្ធ...........................................................................................iii
មាតិកា........................................................................................................ v
សេចក្តីផ្តើម ................................................................................................... ១
I. ផ្នែកទី១ ពិសោធន៍ថ្នាក់ទី១០ ..........................................................................២
ប្រធានបទទី១៖ ការកំណត់អត្តសញ្ញាណផូស៊ីល .......................................................២
១.១- សេចក្តីណែនាំសម្រាប់គ្រូ ..............................................................................២
១.២- ឧបករណ៍ Check List..................................................................................២
១.៣- សន្លឹកកិច្ចការពិសោធន៍ ............................................................................... ៤
ប្រធានបទទី២៖ ការធ្វើចម្រោះទឹក ...................................................................... ៨
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................. ៨
១.២- ឧបករណ៍ Check List................................................................................. ៨
១.៣- សន្លឹកកិច្ចការពិសោធន៍ ............................................................................. ១០
ប្រធានបទទី៣៖ ការកំណត់អត្តសញ្ញាណអាស៊ីតនៅក្នុងប្រភពទឹកផ្សេងៗគ្នា ................................. ១៤
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................... ១៤
១.២- ឧបករណ៍ Check List............................................................................... ១៤
១.៣- សន្លឹកកិច្ចការពិសោធន៍ ............................................................................. ១៦
ប្រធានបទទី៤៖ ការប្រើប្រាស់សីតុណ្ហមាត្រ ........................................................... ២០
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................ ២០
១.២- ឧបករណ៍ Check List................................................................................ ២០
១.៣- សន្លឹកកិច្ចការពិសោធន៍ ............................................................................. ២២

ប្រធានបទទី៥៖ មូលហេតុខ្យល់បក់.......................................................................................... ២៥
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................................ ២៥
១.២- ឧបករណ៍ Check List.................................................................................................. ២៥
១.៣- សន្លឹកកិច្ចការពិសោធន៍ ................................................................................................ ២៧
ប្រធានបទទី៦៖ បន្ទេរកម្តៅក្នុងបរិយាកាស ............................................................................... ៣១
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................................ ៣១
១.២- ឧបករណ៍ Check List.................................................................................................. ៣១
១.៣- សន្លឹកិច្ចការពិសោធន៍ .................................................................................................. ៣៣
II. ផ្នែកទី២ ពិសោធន៍ថ្នាក់ទី១១............................................................................................ ៣៧
ប្រធានបទទី១៖ ចរន្តវង្វល់ និងការរសាត់នៃទ្វីប ........................................................................ ៣៧
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................................ ៣៧
១.២- ឧបករណ៍ Check List.................................................................................................. ៣៧
១.៣- សន្លឹកកិច្ចការពិសោធន៍ ................................................................................................ ៣៩
ប្រធានបទទី២៖ របាយទឹកលើផែនដី ........................................................................................ ៤១
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................................ ៤១
១.២- ឧបករណ៍ Check List.................................................................................................. ៤១
១.៣- សន្លឹកកិច្ចការពិសោធន៍ ................................................................................................ ៤៣
ប្រធានបទទី៣៖ ការវាស់កម្រិតកំណកអំបិលក្នុងប្រភេទទឹកផ្សេងៗ .................................................. ៤៦
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................................ ៤៦
១.២- ឧបករណ៍ Check List.................................................................................................. ៤៦
១.៣- សន្លឹកកិច្ចការពិសោធន៍ ................................................................................................ ៤៨
ប្រធានបទទី៤៖ ការប្រែប្រួលសម្ពាធនិងសីតុណ្ហភាព.................................................................... ៥១
១.១- សេចក្តីណែនាំសម្រាប់គ្រូ ............................................................................................ ៥១

១.២- ឧបករណ៍ Check List............................................................................................ ៥១
១.៣- សន្លឹកកិច្ចការពិសោធន៍ ...........................................................................................៥៣
ប្រធានបទទី៥៖ រដូវទាំង៤ នៅក្នុងតំបន់អាកាសធាតុត្រជាក់បង្គួរ .................................................. ៥៥
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................... ៥៥
១.២- ឧបករណ៍ Check List............................................................................................ ៥៥
១.៣- សន្លឹកកិច្ចការពិសោធន៍ ...........................................................................................៥៧
ប្រធានបទទី៦៖ ការកកើតពពក ....................................................................................... ៦១
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................... ៦១
១.២- ឧបករណ៍ Check List............................................................................................ ៦១
១.៣- សន្លឹកកិច្ចការពិសោធន៍ ...........................................................................................៦៣
III. ផ្នែកទី៣ ពិសោធន៍ថ្នាក់ទី១២ ................................................................................... ៦៦
ប្រធានបទទី១៖ ការធ្វើចំណែកថ្នាក់សិលា.......................................................................... ៦៦
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................... ៦៦
១.២- ឧបករណ៍ Check List............................................................................................ ៦៦
១.៣- សន្លឹកកិច្ចការពិសោធន៍ ...........................................................................................៦៧
ប្រធានបទទី២៖ ការកំណត់វាយភាពនៃដី ...........................................................................៧៣
១.១- សេចក្តីណែនាំសម្រាប់គ្រូ ...........................................................................................៧៣
១.២- ឧបករណ៍ Check List............................................................................................៧៣
១.៣- សន្លឹកកិច្ចការពិសោធន៍ ........................................................................................... ៧៥
ប្រធានបទទី៣ ៖ ការសង្កេតការប្រែប្រួលតារានិករតាមរដូវ................................................... ៨០
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................... ៨០
១.២- ឧបករណ៍ Check List............................................................................................ ៨០
១.៣- សន្លឹកកិច្ចការពិសោធន៍ ........................................................................................... ៨២

ប្រធានបទទី៤៖ បាតុភូតគ្រោស ........................................................................................ ៨៦
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................ ៨៦
១.២- ឧបករណ៍ Check List ........................................................................................ ៨៦
១.៣- សន្លឹកកិច្ចការពិសោធន៍ ........................................................................................ ៨៧
ប្រធានបទទី៥៖ កំណើនកម្តៅផែនដីដោយឧស្ម័នផ្ទះកញ្ចក់ ........................................................................................ ៩០
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................ ៩០
១.២- ឧបករណ៍ Check List ........................................................................................ ៩០
១.៣- សន្លឹកកិច្ចការពិសោធន៍ ........................................................................................ ៩២
ប្រធានបទទី៦៖ ការញែកសំណល់រឹង ........................................................................................ ៩៦
១.១- សេចក្តីណែនាំសម្រាប់គ្រូ ........................................................................................ ៩៦
១.២- ឧបករណ៍ Check List ........................................................................................ ៩៦
១.៣- សន្លឹកកិច្ចការពិសោធន៍ ........................................................................................ ៩៨
សេចក្តីសន្និដ្ឋាន ........................................................................................ ១០១
ឯកសារយោង ........................................................................................ ១០២

# សេចក្តីផ្តើម

សៀវភៅពិសោធន៍ផែនដី និងបរិស្ថានវិទ្យាគឺជាឯកសារដ៏សំខាន់សម្រាប់គ្រូនិងសិស្សានុសិស្ស ថ្នាក់ទី១០ទី១១និងទី១២។ សៀវភៅនេះមានប្រធានបទពិសោធន៍ចំនួន១៨ដែលគ្របដណ្តប់លើខ្លឹមសារសំខាន់ៗជាច្រើនក្នុងមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា។ ប្រធានបទពិសោធន៍ទាំងនេះត្រូវបានរៀបចំឡើងដោយយកចិត្តទុកដាក់ ដើម្បីឱ្យសមស្របទៅនឹងកម្រិតថ្នាក់នីមួយៗ ដែលជំរុញសិស្សឱ្យមានឱកាសអនុវត្តជំនាញវិទ្យាសាស្ត្រជាមូលដ្ឋាន ស្វែងយល់អំពីបាតុភូតធម្មជាតិផ្សេងៗ បង្កើនចំណាប់អារម្មណ៍របស់សិស្ស និងឆ្លុះបញ្ចាំងពីការរីកចម្រើនថ្មីៗក្នុងមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា។

សម្ភារៈដែលប្រើប្រាស់ក្នុងពិសោធន៍ទាំងនេះ សុទ្ធសឹងតែជាសម្ភារៈដែលងាយរកបាននៅក្នុង មូលដ្ឋាន និងមានសុវត្ថិភាព។ ក្រុមបច្ចេកទេសបានដាក់បញ្ចូលនូវលំនាំពិសោធន៍ថ្មីៗ រួមជាមួយនឹងវីដេអូណែនាំសម្រាប់ប្រធានបទនីមួយៗ ដូចជា ការប្រើប្រាស់សីតុណ្ហមាត្រ ការកំណត់អត្តសញ្ញាណផូស៊ីល ការកកើតពពក...។

គោលបំណងនៃសៀវភៅណែនាំនេះគឺ៖

១. ផ្តល់នូវលំនាំច្បាស់លាស់សម្រាប់ការបង្រៀនផែនដីនិងបរិស្ថានវិទ្យាសាស្ត្រតាមរយៈការពិសោន៍។

២. ជំរុញឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀនសូត្រ។

៣. អភិវឌ្ឍជំនាញវិទ្យាសាស្ត្រសំខាន់ៗ ដូចជាការសង្កេត ការវាស់វែង ការវិភាគទិន្នន័យ និងការធ្វើសេចក្តីសន្និដ្ឋាន។

៤. បង្កើនការយល់ដឹងអំពីគោលការណ៍វិទ្យាសាស្ត្រ និងការអនុវត្តពិតៗ។

៥. លើកកម្ពស់ការគិតស៊ីជម្រៅ និងជំនាញដោះស្រាយបញ្ហា។

យើងខ្ញុំសង្ឃឹមថា សៀវភៅពិសោធន៍នេះនឹងជួយលើកកម្ពស់ការយល់ដឹងរបស់សិស្សអំពីផែនដី និងបរិស្ថានវិទ្យា និងជំរុញឱ្យពួកគេមានចំណាប់អារម្មណ៍កាន់តែខ្លាំង ក្នុងការស្វែងយល់អំពីពិភពលោកជុំវិញខ្លួន។ សូមឱ្យសិស្សទាំងអស់ទទួលបានជោគជ័យក្នុងការសិក្សា និងរីករាយនឹងដំណើរស្វែង យល់អំពី វិទ្យាសាស្ត្រ!

# I. ផ្នែកទី១ ពិសោធន៍ថ្នាក់ទី១០
## ប្រធានបទទី១៖ ការកំណត់អត្តសញ្ញាណផូស៊ីល
## ថ្នាក់ទី១០ ជំពូក២ មេរៀនទី៤

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី៤ បញ្ហាបរិស្ថានសំខាន់ៗ ទំព័រ៤០ បានរៀនរួចហើយ។<br>**ប្រធានបទ៖ ការកំណត់អត្តសញ្ញាណផូស៊ីល** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| ☐ សម្ភារៈបានរៀបចំរួចរាល់រួមមាន៖ សំណាកផូស៊ីលផ្សេងៗ កែវពង្រីក តារាងកំណត់អត្តសញ្ញាណ<br>ផូស៊ីល ឬកម្មវិធី Google lens ក្រដាស (សន្លឹកកិច្ចការ)ខ្មៅដៃ បន្ទាត់<br>☐ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីការកំណត់អត្តសញ្ញាណផូស៊ីល ហើយបានចែកឱ្យសិស្សរួចរាល់<br>☐ បានត្រៀមវីដេអូអំពីដំណើរ**ការកំណត់អត្តសញ្ញាណផូស៊ីល**<br>☐ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | ☐ បានរកសម្ភារៈគ្រប់គ្រាន់<br><br>☐ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ<br><br>☐ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| ☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>☐ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>☐ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ។<br>☐ បោសសម្អាតបន្ទប់<br><br>☐ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>☐ បញ្ចាំងវីដេអូ (**ការកំណត់អត្តសញ្ញាណផូស៊ីល**) | ☐ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធ<br>☐ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល |

| | |
|---|---|
| □ ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ | □ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្ដីផ្ដើម

ផូស៊ីលគឺជាសំណល់ ឬស្លាកស្នាមនៃសត្វ និងរុក្ខជាតិ ដែលរស់នៅកាលពីយូរលង់ណាស់មកហើយ។ វាជាភស្តុតាងដ៏សំខាន់ ដែលជួយឱ្យយើងស្វែងយល់អំពីជីវិតនៅលើផែនដីក្នុងសម័យបុរេប្រវត្តិ។ ផូស៊ីលត្រូវបានរកឃើញនៅក្នុងស្រទាប់សិលាកម្ទេចកំណដែលមានអាយុកាលរាប់លានឆ្នាំមុន។ ការសិក្សាអំពីផូស៊ីលជួយឱ្យអ្នកវិទ្យាសាស្ត្រអាចស្វែងយល់អំពីការវិវត្ត និងជីវិតដែលធ្លាប់រស់នៅលើភពផែនដី។

### ខ- វត្ថុបំណង

- កំណត់អត្តសញ្ញាណនៃផូស៊ីល (កំណត់ប្រភេទ ឈ្មោះ អាយុ និងសម័យកាល)។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាបែបគម្រោង។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | សំណាកផូស៊ីលផ្សេងៗ |  |
| ២ | កែវពង្រីក | |

| | | |
|---|---|---|
| | |  |
| ៣ | តារាងកំណត់អត្តសញ្ញាណផូស៊ីល ឬកម្មវិធី Google lens |  |
| ៤ | ក្រដាស( សន្លឹកកិច្ចការ ) |  |
| ៥ | ខ្មៅដៃ |  |
| ៦ | បន្ទាត់ |  |

## គ.២- ដំណើរការពិសោធន៍

| សកម្មភាពគ្រូ | សកម្មភាពសិស្ស |
|---|---|
| • ចែកសិស្សជាក្រុម<br>• កំណត់តួនាទីសមាជិកក្រុម<br>• ណែនាំ និងចែកសន្លឹកកិច្ចការពិសោធន៍<br>• គ្រូត្រៀមសម្ភារៈឱ្យសិស្ស ឬឱ្យសិស្សស្វែងរកខ្លួនឯង<br>• ពន្យល់ដោយសង្ខេបពីនិយមន័យផូស៊ីល និងរបៀបដែលវាកកើត។ | • សិស្សចូលតាមក្រុម<br>• សិស្សបែងចែកភារកិច្ចក្នុងក្រុម<br>• ស្តាប់ការណែនាំ និងទទួលសន្លឹកកិច្ចការពីគ្រូ<br>• សិស្សទទួលសម្ភារៈពីគ្រូយកទៅអនុវត្ត ឬស្វែងរកខ្លួនឯង<br>• ពិភាក្សាគ្នាពីសារៈសំខាន់របស់ផូស៊ីលក្នុងការសិក្សាពីប្រវត្តិកពផែនដី។ |

**ជំហានទី១៖ ការរៀបចំសម្ភារៈ**

- យកសម្ភារទាំងអស់មកដាក់លើតុ
- ណែនាំអំពីដំណើការនៃការធ្វើអត្តសញ្ញាណផូស៊ីល។

**ជំហានទី២៖ ការត្រួតពិនិត្យផូស៊ីល**

- ប្តូរវេនក្រុម ដើម្បីពិនិត្យផូស៊ីលនីមួយៗ



- ប្រើកែវពង្រីកដើម្បីពិនិត្យព័ត៌មានលម្អិត



- វាស់ផូស៊ីលនីមួយៗដោយប្រើបន្ទាត់ និងកត់ត្រារិមាត្រ



**ជំហានទី៣៖ ការកំណត់អត្តសញ្ញាណផូស៊ីល**

- ប្រើតារាងដែលផ្តល់ឱ្យ ឬកម្មវិធី Google Lens ក្នុងទូរស័ព្ទដៃដើម្បីកំណត់អត្តសញ្ញាណផូស៊ីលនីមួយៗ

- កត់ត្រាការសង្កេត និងកំណត់អត្តសញ្ញាណផូស៊ីលរបស់ពួកគេនៅលើសន្លឹកកិច្ចការ។

**ឃ- លទ្ធផល**

- បង្ហាញលទ្ធផលពិសោធន៍
- ដាក់តម្រៀបឧបករណ៍ ពិនិត្យសំណាក់ជួរ និងសង្កេតពីភាពខុសគ្នានៃឧបករណ៍។

**ង- សំណួរពិភាក្សា**

ក- តើក្រុមណាដែលកំណត់អត្តសញ្ញាណផូស៊ីលបានល្អជាងគេ?

ខ- តើក្រុមនោះមានការពិសោធដូចម្តេចខ្លះ?

គ- តំណាងក្រុមនោះទទួលបានចែករំលែកការពិសោធរបស់ខ្លួនហើយពន្យល់ថា តើហេតុអ្វីពួកគេសម្រេចចិត្តរៀបបែបនោះ។

**ច- សន្និដ្ឋាន**

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- តើផូស៊ីលមានសារៈសំខាន់អ្វីខ្លះសម្រាប់អ្នកវិទ្យាសាស្ត្រ? ហេតុអ្វី?

២- តើការស្គាល់អត្តសញ្ញាណផូស៊ីលមានសារៈប្រយោជន៍បែបណាខ្លះ សម្រាប់ការស្រាវជ្រាវបែបវិទ្យាសាស្ត្រ?

# ប្រធានបទទី២៖ ការធ្វើចម្រោះទឹក

# ថ្នាក់ទី១០ ជំពូក២ មេរៀនទី៤

## ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និង រយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី៤ បញ្ហាបរិស្ថានសំខាន់ៗ ទំព័រ៤០ បានរៀនរួចហើយ<br>**ប្រធានបទ៖ ការធ្វើចម្រោះទឹក** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br><br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| □ សម្ភារៈបានរៀបចំរួចរាល់រួមមានទឹកល្អក់ពីប្រភពណាមួយ ខ្សាច់គ្រាប់ធំ(គ្រើម) ខ្សាច់គ្រាប់តូច(ហ្មត់) ធុងអុស សំឡី ដបជ័រចំណុះ១.៥លីត្រ ឬធំជាងនេះ និងគម្រប ថ្មគ្រាប់តូច(ទំហំ១-២cm) ថ្មតូចៗ ទំហំ ០.៥-១cm(ថ្មម៉ិច) ដែករីងមុតស្រួចសម្រាប់ចោះរន្ធ កាំបិត សំពត់កប្បាស ឬកំណាត់អំបោះសស្អាត កូនកែវថ្លាស្អាត សម្រាប់ដាក់ទឹកចម្រោះ ស្បៃរែងខ្សាច់ ថាសឬកាធុន ធុងទឹក ញញួរ កន្ត្រៃ<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការចម្រោះទឹក ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូ អំពីដំណើរការចម្រោះទឹក<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍ |

| | |
|---|---|
| □ បញ្ចាំងវីដេអូ(**ការធ្វើចម្រោះទឹក**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ | □ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br><br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

ការប្រើប្រាស់ប្រភពទឹកមានសុវត្ថិភាពដូចជា កន្លែងទឹកចេញ ឬអណ្តូងដែលមានការការពារ គឺល្អប្រសើរជាងការបន្សុទ្ធទឹកដែលបានមកពីប្រភពទឹកមានភាពកខ្វក់ដូចជា ទន្លេ ឬប្រហោងទឹក (អណ្តូងទឹក ជីកដោយដៃ)។ ទោះជាយ៉ាងណាក៏ដោយ ទឹកមកពីគ្រប់ប្រភពត្រូវតែឆ្លងកាត់ការបន្សុទ្ធជាមុនសិន ប្រសិនបើវាមានភាពកខ្វក់ទឹកដោយសារពណ៌ រសជាតិ ឬត្រូវបានយកមករក្សាទុកនៅក្នុងផ្ទះ (ទឹកដែលចេញពីប្រព័ន្ធបំពង់ អាងស្តុកទឹក និងអណ្តូងក៏ត្រូវតែមានការបន្សុទ្ធមុននឹងផឹកដែរ បើវាត្រូវបានធ្វើឱ្យកខ្វក់)។ មធ្យោបាយបន្សុទ្ធទឹកដែលអ្នកជ្រើសរើសអាស្រ័យលើបរិមាណទឹកដែលអ្នកត្រូវការ តើវត្ថុអ្វីដែលធ្វើឱ្យទឹកកខ្វក់? តើអ្នកនឹងរក្សាទុកវាដោយរបៀបណា? តើធនធានអ្វីខ្លះដែលមាន? ទោះបីអ្នកបន្សុទ្ធដោយវិធីណាក៏ដោយ ជាការល្អបំផុតគួរទុកទឹកឱ្យរង ទើបចាក់វាទៅក្នុងធុងទឹកមួយទៀត ឬគួរច្រោះទឹកសិន មុននឹងរម្ងាប់មេរោគ ការធ្វើដូច្នេះអាចបំបាត់កម្ទេចល្អិតបាន។ ការច្រោះកម្ទេចល្អិតៗចោល ធ្វើឱ្យការរម្ងាប់ មេរោគមានភាពងាយស្រួល ឬកាន់តែមានប្រសិទ្ធភាព។

មធ្យោបាយដែលបង្ហាញនៅទីនេះ មិនបានធ្វើឱ្យទឹកមានសុវត្ថិភាពពីសារធាតុគីមីពុលទេ។ ទឹកដែលមានសារធាតុគីមីពុលគ្មានសុវត្ថិភាពសម្រាប់ផឹក ងូត ឬបោកគក់ទេ វាអាចបណ្តាលឱ្យកើតជំងឺមហារីក កន្ទួលស្បែក រលូតកូន ឬបញ្ហាសុខភាពដទៃទៀតផង។

### ខ-វត្ថុបំណង

- កែច្នៃទឹកល្អក់មកជាទឹកថ្លាតាមរយៈវិធីចម្រោះទឹក។

### គ-វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាបែបគម្រោង។

### គ.១-សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធន៍រួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | ទឹកល្អក់ដែលបានពីប្រភពណាមួយ |  |

| | | |
|---|---|---|
| ២ | ខ្សាច់គ្រាប់ធំ(គ្រើម) |  |
| ៣ | ខ្សាច់គ្រាប់តូច(ហ្មត់) | |
| ៤ | ធ្យូងអុស |  |
| ៥ | សំឡី |  |
| ៦ | ដបជ័រចំណុះ១.៥L ឬធំជាងនេះ និងគម្រប |  |
| ៧ | ថ្មគ្រាប់តូច(ទំហំ១-២cm) |  |
| ៨ | ថ្មតូចៗទំហំ0.៥-១cm(ថ្មម៉ិច) |  |
| ៩ | ដែករឹងមុតស្រួចសម្រាប់ចោះរន្ធ |  |
| ១០ | កាំបិត |  |
| ១១ | សំពត់កប្បាស ឬកំណាត់អំបោះសស្អាត |  |
| ១២ | កូនកែវថ្លាស្អាត សម្រាប់ដាក់ទឹកចម្រោះ |  |
| ១៣ | ស្បែរវែងខ្សាច់ | |

| | | |
|---|---|---|
| ១៤ | ថាស ឬកាធុន | |
| ១៥ | ធុងទឹក | |
| ១៦ | ញញួរ | |
| ១៧ | កន្ត្រៃ | |

**គ.២-ដំណើរការពិសោធន៍**

**ជំហានទី១៖ ការរៀបចំសម្ភារៈសម្រាប់ធ្វើឧបករណ៍ចម្រោះទឹក**





- យកដបជ័រមួយមកកាត់ផ្នែកខាងក្រោមចេញ (ដូចក្នុងរូប) រួចហើយចោះរន្ធលើគម្របដប៣រន្ធ បន្ទាប់មកបិទគម្របដបឱ្យជិត

**ជំហានទី២៖ ការដំឡើងឧបករណ៍ចម្រោះ**

- ដាក់កំណាត់អំបោះនៅផ្នែកបាតនៃកំណាត់ដបជ័រទី១យ៉ាងតិច២ស្រទាប់
- ដាក់សំឡីនៅបន្ទាប់ពីកំណាត់អំបោះយ៉ាងតិច ៥cm
- ដាក់ខ្សាច់គ្រាប់ល្អិតដែលបានលាងរួចកម្រាស់.....cm
- ដាក់ខ្សាច់គ្រាប់ធំដែលបានលាងរួចកម្រាស់.....cm
- ដាក់ដុំធ្យូងកម្រាស់........cm
- ដាក់ថ្មគ្រាប់តូចទំហំ០.៥-១cm កម្រាស់.....cm
- ដាក់ថ្មគ្រាប់តូចទំហំ១-២cm កម្រាស់.....cm
- បន្ទាប់មកដាក់ឧបករណ៍ដែលដំឡើងរួចនោះលើកែវបេស៊ែ
- បន្ទាប់មកយកទឹកដែលល្អក់ចាក់ចូលក្នុងឧបករណ៍ចម្រោះដោយល្បឿនយឺតៗ
- សង្កេតមើលភាពថ្លារបស់ទឹកដែលស្រក់ចុះនៅក្នុងកែវបេស៊ែរខាងក្រោមថាតើប្រែប្រួលដូចម្តេច?

**ឃ-លទ្ធផល**

- បង្ហាញលទ្ធផលពិសោធន៍
- ដាក់តម្រៀបឧបករណ៍ចម្រោះ និងទឹកចម្រោះជាជួរ និងសង្កេតពីភាពខុសគ្នានៃឧបករណ៍។

**ខ-សំណួរពិភាក្សា**

ក- តើទឹកក្រុមណាដែលច្រោះបានល្អ ឬថ្លាជាងគេ?

ខ- តើក្រុមនោះរៀបចំឧបករណ៍ចម្រោះពិសោធន៍ដូចម្តេច?

គ- តំណាងក្រុមចែករំលែកការពិសោធរបស់ខ្លួន ហើយពន្យល់ថា តើហេតុអ្វីពួកគេសម្រេចចិត្តរៀបបែបនះ?

## ច-សន្និដ្ឋាន

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

.................................................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- តើទឹកដែលច្រោះបាននេះអាចបរិភោគបានដែរឬទេ? ហេតុអ្វី?

២- តើទឹកដែលច្រោះបាននេះអាចប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះ?

៣- ចូរប្អូនៗបង្កើតឧបករណ៍ចម្រោះទឹកដោយខ្លួនឯងសម្រាប់ច្រោះទឹកនៅតាមគេហដ្ឋានរៀងៗខ្លួន។

# ប្រធានបទទី៣៖ ការកំណត់អត្តសញ្ញាណអាស៊ីតនៅក្នុងប្រភពទឹកផ្សេងៗគ្នា

## ថ្នាក់ទី១០ ជំពូក២ មេរៀនទី៤

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវធ្វើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី៤ បញ្ហាបរិស្ថានសំខាន់ៗ ទំព័រ៤០ បានរៀនរួចហើយ<br>**ប្រធានបទ៖ ការកំណត់អត្តសញ្ញាណអាស៊ីតនៅក្នុងប្រភពទឹកផ្សេងៗគ្នា** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

<table>
<tr><td>□ សម្ភារៈបានរៀបចំរួចរាល់រួមមាន សូលុយស្យុងមេនំប៉័ង(Baking Soda) ពែងថ្លាតូចៗ ឬបំពង់ សាក ឬកែវបែស៊ែ(៥-៦ សម្រាប់ក្រុមនីមួយៗ)ក្រដាសធ្វើតេស្ត pH គំរូទឹកពីប្រភពផ្សេងៗ (ទឹកម៉ាស៊ីន ទឹកសុទ្ធ ទឹកត្រពាំង/បឹង ទឹកភ្លៀង។ល។)វ៉ែនតាសុវត្ថិភាព និងស្រោមដៃទឹកខ្មេះ និងដងកូរ<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីការកំណត់អត្តសញ្ញាណអាស៊ីតនៅក្នុងប្រភពទឹកផ្សេងៗគ្នា។ ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីការកំណត់អត្តសញ្ញាណអាស៊ីតនៅក្នុងប្រភពទឹកផ្សេងៗគ្នា<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។</td><td>□ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។</td></tr>
<tr><td colspan="2">ពេលធ្វើពិសោធន៍ (☑ Check list)</td></tr>
<tr><td>គ្រូ</td><td>សិស្ស</td></tr>
<tr><td>□ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត និងតាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។</td><td>□ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។</td></tr>
<tr><td colspan="2">ក្រោយពិសោធន៍ (☑ Check list)</td></tr>
<tr><td>គ្រូ</td><td>សិស្ស</td></tr>
</table>

| | |
|---|---|
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (**ការកំណត់អត្តសញ្ញាណអាស៊ីតនៅក្នុងប្រភពទឹកផ្សេងៗគ្នា**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ **ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br><br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្ដីផ្ដើម

ទឹក គឺជាធនធានសំខាន់បំផុតសម្រាប់ជីវិត។ យ៉ាងណាមិញ គុណភាពទឹកអាចប្រែប្រួលអាស្រ័យទៅលើប្រភពរបស់វា។ កត្តាមួយដែលមានឥទ្ធិពលយ៉ាងខ្លាំងលើគុណភាពទឹក គឺកម្រិត pH របស់វា ដែលគេវាស់ជាអាស៊ីត ឬបាសរបស់ទឹក។ ការយល់ដឹងអំពីកម្រិត pH របស់ប្រភពទឹកផ្សេងៗ គ្នាអាចជួយយើងវាយតម្លៃសុខភាពបរិស្ថាន និងភាពសមស្របរបស់វាសម្រាប់ការប្រើប្រាស់ផ្សេងៗ។

### ខ- វត្ថុបំណង

- ប្រៀបធៀបកម្រិតអាស៊ីតនៃប្រភពទឹកផ្សេងៗ ដោយប្រើសូចនាករ pH តាមរយៈការធ្វើតេស្ត។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាបែបរិះរក។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | សូលុយស្យុងមេទំប៉ុង (Baking Soda) |  |
| ២ | ពែងថ្លាតូចៗ ឬបំពង់សាក ឬ កែវបែស៊ែ (៥-៦ សម្រាប់ក្រុមនីមួយៗ) |   |

| | | |
|---|---|---|
| ៣ | ក្រដាសធ្វើតេស្ត pH |  |
| ៤ | គំរូទឹកពីប្រភពផ្សេងៗ ( ទឹកម៉ាស៊ីន ទឹកសុទ្ធ ទឹកត្រពាំង/បឹង ទឹកភ្លៀង។ល។ ) |  |
| ៥ | វ៉ែនតាសុវត្ថិភាព និងស្រោមដៃ | |
| ៦ | ទឹកខ្មេះ |  |
| ៧ | ដងកូរ | |

## គ.២- ដំណើរការពិសោធន៍

| គ្រូ | សិស្ស |
|---|---|
| • ចែកសិស្សជាក្រុម<br>• កំណត់តួនាទីសមាជិកក្រុម<br>• ណែនាំ និងចែកសន្លឹកកិច្ចការពិសោធន៍<br>• គ្រូត្រៀមសម្ភារៈឱ្យសិស្ស ឬឱ្យសិស្សស្វែងរកខ្លួនឯង ដូចជាទឹកភ្លៀង ទឹកបឹង ទឹកស្រះ... ។ | • សិស្សចូលតាមក្រុម<br>• សិស្សបែងចែកភារកិច្ចក្នុងក្រុម<br>• ស្តាប់ការណែនាំ និងទទួលសន្លឹកកិច្ចការពីគ្រូ<br>• សិស្សទទួលសម្ភារៈពីគ្រូយកទៅអនុវត្ត ឬស្វែងរកខ្លួនឯង។ |

**ជំហានទី១៖ ការរៀបចំសម្ភារៈ**

- ពាក់វ៉ែនតាសុវត្ថិភាព និងស្រោមដៃ
- សរសេរឈ្មោះប្រភពទឹកនីមួយៗនៅលើពែង ឬបំពង់សាកនីមួយៗ
- ចាក់ទឹកបន្តិច(ប្រហែល ២0ml) ពីសំណាកទឹកនីមួយៗទៅក្នុងពែង ឬបំពង់សាកដែលត្រូវគ្នា
- បន្ថែមទឹកខ្មេះទៅក្នុងពែងមួយហើយសរសេរស្លាក «ទឹកខ្មេះ(អាស៊ីត)»

- បន្ថែមសូលុយស្យុងមេនំប៉័ង ( Baking Soda ) ទៅក្នុងពែងមួយទៀតហើយសរសេរស្លាក «មេនំប៉័ង( បាស )»
- ធ្វើតេស្តសំណាកទឹកដោយប្រើក្រដាស pH ជ្រលក់ទៅក្នុងសំណាកនីមួយៗរយៈពេល ២ ទៅ៣វិនាទី បន្ទាប់មកប្រៀបធៀបពណ៌ទៅនឹងតារាង pH
- កត់ត្រាពណ៌របស់ក្រដាស pH និងតម្លៃ pH នៅក្នុងតារាងទិន្នន័យខាងក្រោម៖

| **ប្រភពទឹក** | **ពណ៌ក្រដាស** pH | **តម្លៃ pH** | **ជាអាស៊ីត/ណឺត/បាស** |
|---|---|---|---|
| ទឹកម៉ាស៊ីន | | | |
| ទឹកសុទ្ធ | | | |
| ទឹកត្រពាំង/បឹង | | | |
| ទឹកភ្លៀង | | | |
| ទឹកខ្មេះ(អាស៊ីត ) | | | |
| សូលុយស្យុងមេនំប៉័ង ( បាស ) | | | |

**ជំហានទី២៖** ( ការវាយតម្លៃ៖ QCM ឆ្លើយសំណួរគិតកម្រិតខ្ពស់ ( Bloom ) របាយការណ៍ពិសោធននិងបទបង្ហាញរបស់សិស្ស...... )

**ជំហានទី៣៖ ការបង្ហាញលទ្ធផល និងសន្និដ្ឋាន**

- ឱ្យសិស្សបង្ហាញលទ្ធផលពិសោធន៍
- គ្រូសម្របសម្រួលលទ្ធផលដែលបានរកឃើញ ដោយសួរសំណួរអំពីលទ្ធផលដែលបានរកឃើញ ដូចជា៖

១- តើប្រភពទឹកមួយណាដែលមានជាតិអាស៊ីតខ្លាំងជាងគេ ? តើអ្នកដឹងដោយរបៀបណា ?
២- តើប្រភពទឹកមួយណាដែលមានជាតិបាសខ្លាំងជាងគេ ? តើអ្នកដឹងដោយរបៀបណា ?
៣- តើ pH របស់ប្រភពទឹកធម្មជាតិ( ត្រពាំង/បឹង ទឹកភ្លៀង ) ធៀបទៅនឹងទឹកម៉ាស៊ីន និងទឹកសុទ្ធខុសគ្នាយ៉ាងដូចម្តេច ?
៤- តើកត្តាអ្វីខ្លះដែលអាចជះឥទ្ធិពលដល់ pH របស់ទឹកនៅក្នុងប្រភពធម្មជាតិ ?
៥- តើការតាមដាន pH របស់ប្រភពទឹកនៅក្នុងបរិស្ថានមានសារៈសំខាន់ឬទេ ? ហេតុអ្វី ?

**ឃ- លទ្ធផល**

**ការវាយតម្លៃ៖** ឱ្យសិស្សពិភាក្សាជាក្រុមអំពី៖

- កត្តាដែលប៉ះពាល់ដល់ pH របស់ទឹក ( ឧ. រ៉ែរលាយក្នុងទឹក $CO_2$ក្នុងបរិយាកាស ការបំពុល )
- សារៈសំខាន់នៃ pH សម្រាប់ជីវិតក្នុងទឹក និងសុខភាពប្រព័ន្ធអេកូឡូស៊ី
- សកម្មភាពរបស់មនុស្សដែលអាចផ្លាស់ប្តូរ pH របស់ទឹក ( ឧ. ទឹកភ្លៀងអាស៊ីត ការហូរចេញពីកសិកម្ម )
- វិធីសាស្ត្រសម្រាប់សម្អាតទឹកដែលមានជាតិអាស៊ីត ឬបាស។

## ង- សំណួរពិភាក្សា

ក- តើទឹកក្រុមណាដែលរកបានទិន្នន័យសុក្រិតជាងគេ?

ខ- តើក្រុមនោះរៀបចំដំណើការពិសោធន៍ដូចម្ដេច?

គ- តំណាងក្រុមចែករំលែកការពិសោធរបស់ខ្លួនហើយពន្យល់ថា តើហេតុអ្វីពួកគេសម្រេចចិត្តរៀបបែបនោះ?

## ច- សន្និដ្ឋាន

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- តើការដឹងពីម្រិតជាតិអាស៊ីតនៃប្រភពទឹកផ្សេងមានភាពចាំបាច់អ្វីខ្លះ?

២- តើការដឹងអំពីរបៀបនៃការពិសោធបែបនេះ អាចយកទៅប្រើប្រាស់នៅក្នុងជីវភាពរស់នៅ ឬអាចប្រើប្រាស់សម្រាប់ធ្វើអ្វីខ្លះ?

៣- ចូរប្អូនៗបង្កើតលំនាំនៃការពិសោធនេះដោយខ្លួនឯងសម្រាប់វាស់ជាតិអាស៊ីតនៅក្នុងភេសជ្ជៈនៅតាមគេហដ្ឋានរៀងៗខ្លួន។

# ប្រធានបទទី៤៖ ការប្រើប្រាស់សីតុណ្ហាមាត្រ

## ថ្នាក់ទី១០ ជំពូក៣ មេរៀនទី១

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូអ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
☐ ឆ្លើយសំណួរផ្ទាល់មាត់
☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ បានរៀនរួចហើយមេរៀនខ្យល់បក់នៅថ្នាក់ទី ១០<br>**ប្រធានបទ៖ ការប្រើប្រាស់ឧបករណ៍សីតុណ្ហាមាត្រ** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br><br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| សម្ភារៈបានរៀបចំរួចរាល់រួមមាន ឧបករណ៍វាស់សីតុណ្ហភាព អេឡិចត្រូនិចឬឌីជីថល ទែម៉ូម៉ែត្រ កែវបេស៊ែ ទឹក ប៊ិក ក្រដាសកត់ត្រា វ៉ែនតាខ្មៅ នាឡិកាកំណត់ម៉ោង ប្រអប់ក្រដាស<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីការប្រើប្រាស់ ឧបករណ៍វាស់សីតុណ្ហមាត្រ ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីដំណើរការប្រើប្រាស់ឧបករណ៍វាស់សីតុណ្ហមាត្រ<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់( ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង )។ | □ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** ( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត និងតាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន )។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ។<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** ( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ ( **ការប្រើប្រាស់ឧបករណ៍សីតុណ្ហមាត្រ** ) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ |

| | |
|---|---|
| □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ | □ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

សីតុណ្ហភាព គឺជារង្វាស់នៃចលនាថាមពលរបស់ភាគល្អិតគិតជាមធ្យម។ សីតុណ្ហភាពត្រជាក់ភាគល្អិតធ្វើចលនាកាន់តែយឺត សីតុណ្ហភាពកាន់តែក្តៅ នោះភាគល្អិតធ្វើចលនាកាន់តែលឿន។ សីតុណ្ហភាពក្នុងថ្ងៃនីមួយៗប្រែប្រួលទៅតាមតំបន់ ពេលវេលា រដូវ និងរយៈកម្ពស់កើនឡើង។ ការដឹងពីកម្រិតសីតុណ្ហភាព ជួយយើងក្នុងការសម្របខ្លួនទៅតាមតំបន់រស់នៅ ប្រកបអាជីវកម្ម ធ្វើកសិកម្ម និងចិញ្ចឹមសត្វជាដើម។ តើយើងប្រើប្រាស់ឧបករណ៍អ្វីដើម្បីវាស់សីតុណ្ហភាពនៅក្នុងខ្យល់ ឬក្នុងទឹក? ហើយប្រើដោយរបៀបណា?

### ខ- វត្ថុបំណង

- ប្រើប្រាស់ឧបករណ៍សីតុណ្ហមាត្របានត្រឹមត្រូវ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាបែបគម្រោង។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | ឧបករណ៍វាស់សីតុណ្ហភាព អេឡិចត្រូនិច ឬឌីជីថល |  |
| ២ | ទែម៉ូម៉ែត្រ |  |
| ៣ | កែវបេស៊ែ |  |
| ៤ | ទឹក |  |

| | | |
|---|---|---|
| ៥ | ប៊ិក |  |
| ៦ | ក្រដាសកត់ត្រា |  |
| ៧ | វ៉ែនតាខ្មៅ |  |
| ៨ | នាឡិកាកំណត់ម៉ោង |  |
| ៩ | ប្រអប់ក្រដាស |  |

### គ.២- ដំណើរការពិសោធន៍

| គ្រូ | សិស្ស |
|---|---|
| ▪ ចែកសិស្សជាក្រុម<br>▪ កំណត់តួនាទីសមាជិកក្រុម<br>▪ ណែនាំ និងចែកសន្លឹកកិច្ចការឱ្យសិស្ស<br>▪ ត្រៀមសម្ភារៈឱ្យសិស្ស។ | ▪ ចូលរួមតាមក្រុម<br>▪ បែងចែកភារកិច្ចក្នុងក្រុម<br>▪ ស្ដាប់ការណែនាំ និងទទួលសន្លឹកកិច្ចការ<br>▪ ទទួលយកសម្ភារៈទៅអនុវត្តតាមក្រុម។ |

**ជំហានទី១៖ រៀបចំសម្ភារៈ**

- យកកែវបេស៊ែដាក់ទឹកឱ្យបានប្រហែល១០០០ml
- រៀបចំដាក់ទែម៉ូម៉ែត្របារ៉ែតដាក់ក្នុងកែវបេស៊ែដោយប្រុងប្រយ័ត្ន កុំឱ្យប៉ះកែវ
- រៀបចំដាក់កល់ទែម៉ូម៉ែត្របារ៉ែតលើប្រអប់ក្រដាសឱ្យផុតពីដី (ចុងទែម៉ូម៉ែត្រលយចេញផុតពីប្រអប់ក្រដាស)។

**ជំហានទី២៖ ដំណើរការពិសោធន៍**

- ចាប់ផ្ដើមពាក់វ៉ែនតាខ្មៅការពារពន្លឺថ្ងៃ
- ចាប់ផ្ដើមកត់ត្រាសីតុណ្ហភាពនៅនាទី០ មុនយកទៅដាក់នៅទីតាំងប្រមូលទិន្នន័យ

- យកកែវបេស៊ែមានទឹក រួចដាក់ទែម៉ូម៉ែត្របារ៉តក្នុងទឹកនោះ និងប្រអប់ក្រដាសដែលដាក់ ទែម៉ូម៉ែត្រពីលើទៅកាន់ទីតាំងប្រមូលទិន្នន័យ
- ត្រៀមនាឡិកាកំណត់ម៉ោង រួចកត់ត្រាសីតុណ្ហភាពរៀងរាល់៤នាទីម្តងៗ

**ឃ- លទ្ធផល**

- ឱ្យក្រុមសិស្សបង្ហាញលទ្ធផលពិសោធន៍
- គ្រូត្រូវសម្របសម្រួលលទ្ធផលដែលទទួលបាន ដោយធ្វើការប្រៀបធៀបលទ្ធផលសីតុណ្ហភាពក្នុងទឹក និងខ្យល់ ថាតើវាមានលក្ខណៈដូចគ្នា ប្រហាក់ប្រហែលគ្នា ឬមានលក្ខណៈខុសគ្នា ដូចម្តេច?
- ការវាយតម្លៃ៖ QCM ឆ្លើយសំណួរគិតកម្រិតខ្ពស់(Bloom)
- របាយការណ៍ពិសោធន៍ និងបទបង្ហាញរបស់សិស្ស...
- គ្រូវាយតម្លៃហេតុផលអំពីភាពខុសគ្នារបស់សីតុណ្ហភាពក្នុងនាទីនីមួយៗ
- ស្នើឱ្យក្រុមសិស្សនីមួយៗសង់ក្រាប
- ក្រុមសិស្សនីមួយៗសង្កេតមើលក្រាបរបស់ខ្លួន
- សិស្សបង្ហាញលទ្ធផលរបស់ពួកគេ និងធ្វើសេចក្តីសន្និដ្ឋានតាមក្រុមនីមួយៗ
- គ្រូសម្របសម្រួលចម្លើយរបស់ក្រុមនីមួយៗតាមលក្ខណៈវិទ្យាសាស្ត្រ។

**ង- សំណួរពិភាក្សា**

ក- តើក្រាបសីតុណ្ហភាពខ្យល់មានលក្ខណៈដូចម្តេច?

ខ- តើក្រាបសីតុណ្ហភាពទឹកមានលក្ខណៈដូចម្តេច? ចូរពន្យល់។

**ច- សន្និដ្ឋាន**

បន្ទាប់ពីប្រើប្រាស់ឧបករណ៍សីតុណ្ហមាត្របានត្រឹមត្រូវហើយយើងសង្កេតឃើញថា នៅក្នុងទឹក និងក្នុងខ្យល់មានសីតុណ្ហភាពមិនដូចគ្នាទេ។ ដូច្នេះ ចូរប្អូនៗធ្វើការស្រាវជ្រាវបន្ថែមកេសីតុណ្ហភាពមធ្យមប្រចាំថ្ងៃ ដោយអនុវត្តតាមវិធីបែបនេះ និងស្រាវជ្រាវបន្តទៀតថា ហេតុអ្វីបានជានៅក្នុងទឹក និងខ្យល់មានសីតុណ្ហភាពមិនដូចគ្នានៅពេលវេលាតែមួយ ទីកន្លែងតែមួយ?

........................................................................................................................................

........................................................................................................................................

........................................................................................................................................

........................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- ឧបករណ៍សីតុណ្ហមាត្រ ក្រៅពីប្រើប្រាស់សម្រាប់ការធ្វើពិសោធនេះ តើគេប្រើសម្រាប់ធ្វើអ្វីទៀត?

២- តើឧបករណ៍សីតុណ្ហមាត្រ មានសារប្រយោជន៍អ្វីខ្លះ?

# ប្រធានបទទី៥៖ មូលហេតុខ្យល់បក់

## ថ្នាក់ទី១០ ជំពូក៣ មេរៀនទី២

### ១.១- សេចក្ដីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្ដីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី៤ បញ្ហាបរិស្ថានសំខាន់ៗ ទំព័រ៤០ បានរៀនរួចហើយ។<br>**ប្រធានបទ៖ មូលហេតុខ្យល់បក់** | ☐ បានអាន និងរៀនទ្រឹស្ដីមេរៀន<br><br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| សម្ភារៈបានរៀបចំរួចរាល់រួមមាន កែវបេសើ(កែវក្រិត)បន្ទះឈើ ឬក្រដាសគ្របប្រអប់កញ្ចក់ ទឹកកក ប្រអប់ជ័រ ឬចាន ទៀន ធូបខ្លី និងធូបវែង ដែកកេះ ធុង ឬប្រអប់កញ្ចក់<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការចម្រោះទឹក ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីមូលហេតុខ្យល់បក់<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (**មូលហេតុខ្យល់បក់**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់ |

| | |
|---|---|
| ឆ្លើយសំណួរផ្ទាល់មាត់<br>ធ្វើបទបង្ហាញជាក្រុម<br>លទ្ធផលផលិតបាន។ | ធ្វើបទបង្ហាញជាក្រុម<br>លទ្ធផលផលិតបាន។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

ខ្យល់បក់ ជាចលនារបស់ខ្យល់តាមផ្ទៃដេក ពីតំបន់សម្ពាធខ្លាំងទៅតំបន់សម្ពាធខ្សោយ ហើយមានពីរប្រភេទគឺ ខ្យល់បក់ប្រចាំទី និងខ្យល់បក់ប្រចាំតំបន់។ ខ្យល់បក់ប្រចាំទីគឺជាខ្យល់ដែលធ្វើចលនាក្នុងរយៈចម្ងាយខ្លី ហើយអាចបក់មកពីគ្រប់ទិសទី។ ខ្យល់បក់ប្រចាំតំបន់គឺជាខ្យល់ដែលធ្វើចលនាក្នុងរយៈចម្ងាយវែង ហើយអាចបក់ពីទីកន្លែងជាក់លាក់។

អ្នកធ្លប់ដែរឬទេថា ហេតុអ្វីបានជាពេលខ្លះស្លឹកឈើមានចលនា ពេលខ្លះគ្មានចលនា?(បើមានខ្យល់បក់ ពេលខ្លះបក់តិច ពេលខ្លះបក់ខ្លាំង) តើមូលហេតុអ្វីបានជាធ្វើឱ្យមានចរន្តខ្យល់បក់?

### ខ- វត្ថុបំណង

- បង្ហាញពីមូលហេតុខ្យល់បក់តាមរយៈការពិសោធ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាបែបគម្រោង។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | កែវបេស៊ែ(កែវក្រិត)តូចដាក់ខ្សាច់ ឬវត្ថុផ្សេងៗដែលអាចដោតធូបបាន |  |
| ២ | បន្ទះឈើ ឬក្រដាសគ្របប្រអប់កញ្ចក់ |  |

| | | |
|---|---|---|
| ៣ | ទឹកកក |  |
| ៤ | ប្រអប់ជ័រ ឬចាន |  |
| ៥ | ទៀន |  |
| ៦ | ធូបខ្លី និងធូបវែង |  |
| ៧ | ដែកកេះ |  |

| | | |
|---|---|---|
| | | |
| ៨ | ធុង ឬប្រអប់កញ្ចក់ |  |

**គ.២- ដំណើរការពិសោធន៍**

| គ្រូ | សិស្ស |
|---|---|
| • ចែកសិស្សជា២ក្រុម ហើយប្រគល់សម្ភារៈសម្រាប់ពិសោធន៍ចលនាខ្យល់បក់<br>• គ្រូណែនាំពីការប្រើប្រាស់សម្ភារៈនីមួយៗ៖ ប្រអប់កញ្ចក់ ដែកកេះ ធូបខ្លី និងធូបវែង ទៀន ទឹកកក ប្រអប់ជ័រ បន្ទះឈើឬក្រដាសគ្របប្រអប់កញ្ចក់ កែវបេស៊ែ<br>• គ្រូចែកសន្លឹកកិច្ចការ និងណែនាំពីដំណើរការពិសោធន៍ និងការកត់ត្រា។ | • សិស្សចូលតាមក្រុម ហើយទទួលសម្ភារៈ<br>• ស្តាប់ការណែនាំពីការប្រើប្រាស់សម្ភារៈនីមួយៗ<br>• សិស្សទទួលសន្លឹកកិច្ចការ និងស្តាប់ការណែនាំ<br>• សិស្សធ្វើការពិភាក្សា<br>• សិស្សពិសោធន៍ និងកត់ត្រា។ |

**ជំហានទី១៖ ការរៀបចំសម្ភារៈសម្រាប់ពិសោធន៍ចរន្តខ្យល់បក់**

- ដាក់ទៀនខ្លីចំនួនពីរដើមឱ្យជាប់នៅផ្នែកម្ខាងនៃប្រអប់កញ្ចក់
- ដាក់ប្រអប់ទឹកកកនៅផ្នែកម្ខាងទៀតនៃប្រអប់កញ្ចក់។

**ជំហានទី២៖ ការតម្លើងឧបករណ៍ពិសោធន៍ចរន្តខ្យល់បក់ និងពិសោធន៍ចរន្តខ្យល់បក់**

- អុចទៀនទាំងពីរ
- យកកែវបេស៊ែទៅដាក់ក្នុងប្រអប់កញ្ចក់នៅចន្លោះរវាងទឹកកក និងទៀន
- អុចធូបខ្លីឱ្យឆេះចំនួនបីសរសៃ រួចយកទៅដោតក្នុងកែវបេស៊ែ
- ដាក់បន្ទះឈើ ឬក្រដាសគ្របប្រអប់កញ្ចក់ឱ្យចំផ្នែកកណ្តាល
- អុចធូបវែង៦សរសៃឱ្យឆេះ
- យកធូបវែងផ្នែកដែលឆេះដាក់ផ្ទុយគ្នា៣សរសៃលើបន្ទះក្រដាសគ្របប្រអប់កញ្ចក់។

**ឃ- លទ្ធផល**

- របាយការណ៍ពិសោធន៍ និងបទបង្ហាញរបស់សិស្ស

- ឱ្យសិស្សបង្ហាញលទ្ធផលពិសោធន៍(ផ្សែងធូបអណ្ដែតពីផ្នែកទឹកកកទៅផ្នែកម្ខាងទៀតនៃភ្លើងទៀន)
- គ្រូសម្របសម្រួលលទ្ធផលដែលសិស្សរកឃើញទាំងពីរក្រុម។

**ខ- សំណួរពិភាក្សា**

ក- តើការពិសោធនៃចលនាខ្យល់បក់របស់ក្រុមមួយណាដែលបង្ហាញឃើញបាតុភូតច្បាស់ជាងគេនៃដំណើរការខ្យល់បក់?

ខ- ខ្យល់ដែលបក់នោះហេតុអ្វីបានជាបក់ឡើងទៅលើ ហើយធ្វើចលនាធ្លាក់ចុះក្រោមវិញ?

**ច- សន្និដ្ឋាន**

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- តើខ្យល់ធ្វើចលនាផ្លាស់ទីបានដោយសារអ្វី?

២- នៅពេលយើងដឹងពីដំណើរបស់ខ្យល់បក់ តើមានសារៈសំខាន់អ្វីខ្លះសម្រាប់ការរស់នៅប្រចាំថ្ងៃ?

# ប្រធានបទទី៦៖ បន្ទេរកម្តៅក្នុងបរិយាកាស

## ថ្នាក់ទី១០ ជំពូក២ មេរៀនទី៤

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី៤ បញ្ហាបរិស្ថានសំខាន់ៗ ទំព័រ៤០ បានរៀនរួចហើយ។<br>**ប្រធានបទ៖ ការបន្ទេរកម្តៅ** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br><br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

<table>
<tr><td>សម្ភារៈបានរៀបចំរួចរាល់រួមមានៈចង្ក្រានហ្គាស១ កែវបេសែ១ ធូបចំនួន៣សរសៃ ដែកកេះ១ ទែម៉ូម៉ែត្រ១ ក្រដាសអាលុយមីញ៉ូម១ បន្ទះទម្រកែវបេសែ<br><br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការបន្ទេរកម្តៅ ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីដំណើរការបន្ទេរកម្តៅ<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។</td><td>□ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ<br><br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។</td></tr>
<tr><td colspan="2">ពេលធ្វើពិសោធន៍ (☑ Check list)</td></tr>
<tr><td>គ្រូ</td><td>សិស្ស</td></tr>
<tr><td>□ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។</td><td>□ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br><br>□ អាន និងស្វែងយល់បន្ថែម។</td></tr>
<tr><td colspan="2">ក្រោយពិសោធន៍ (☑ Check list)</td></tr>
<tr><td>គ្រូ</td><td>សិស្ស</td></tr>
<tr><td>□ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (បន្ទេរកម្តៅ) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃៈ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់</td><td>□ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធ<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br><br>□ កិច្ចការវាយតម្លៃៈ<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់</td></tr>
</table>

| | |
|---|---|
| □ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ | □ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

ថាមពលកម្តៅគឺជាការផ្ទេរនៃកម្តៅចេញពីវត្ថុក្តៅទៅវត្ថុត្រជាក់។ កម្តៅបានផ្ទេរទៅតាមមធ្យោបាយ៣យ៉ាងគឺៈ ការចម្លងកម្តៅ ចរន្តវិលវល់ និងរំភាយរស្មី ។

### ខ- វត្ថុបំណង

- បង្ហាញការផ្ទេរកម្តៅពីព្រះអាទិត្យមកផែនដី ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមបែបវិធីវិទ្យាសាស្ត្រ។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមានៈ

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | ចង្ក្រានហ្គាស ចំនួន០១ | ផ្តល់ថាមពល |
| ២ | កែវបេស៊ែ ចំនួន០១ | កែវបេស៊ែមិនបាច់ក្រិតក៏បាន |

| | | |
|---|---|---|
| ៣ | ធូបចំនួន៣សរសៃ | <br>ផ្សែងធូបតំណាងឧស្ម័ន ដើម្បីបង្ហាញចលនារបស់ឧស្ម័ន |
| ៤ | ដែកកេះ | <br>ដុតធូប |
| ៥ | ទែម៉ូម៉ែត្រ០១ | <br>សម្រាប់វាស់សីតុណ្ហភាពមុនពេលនិងអំឡុងពេលពិសោធន៍ |
| ៦ | ក្រដាសអាលុយមីញ៉ូម០១ | <br>ដាក់ខាងលើបន្ទះទម្រ |
| ៧ | បន្ទះទម្រកែវបេស៊ែ | <br>បន្ទះទម្រកែវបេស៊ែ |

## គ.២- ដំណើរការពិសោធន៍




### ជំហានទី១៖ ការរៀបចំសម្ភារៈ

- រៀបចំចង្ក្រានហ្គាស
- ដាក់បន្ទះទម្រកែវបេស៊ែ
- ដាក់សន្លឹកអាលុយមីញ៉ូម
- រៀបចំកែវបេស៊ែ ដោយបិទស្លាកសញ្ញាសម្គាល់ ឧស្ម័ន និងយកបន្ទះប្លាស្ទិកគ្របពីលើមាត់កែវបេស៊ែ
- វាស់សីតុណ្ហភាពមុនពេលបញ្ឆេះចង្ក្រានហ្គាស
- កត់ត្រាតួលេខសីតុណ្ហភាពមុនពេលផ្តល់កម្តៅ។

### ជំហានទី២៖ ដំណើរការពិសោធន៍

- បញ្ឆេះចង្ក្រានហ្គាស
- ដុតធូប រួចយកទៅស៊កចូលក្នុងកែវបេស៊ែ
- បន្ទាប់មកសង្កេតមើលពីចលនារបស់ឧស្ម័ននៅក្នុងកែវ
- វាស់សីតុណ្ហភាពនៅក្នុងកែវម្តងទៀត បន្ទាប់មកកត់ត្រាតួលេខ។

## ឃ- លទ្ធផល

- ការពិនិត្យសន្លឹកកិច្ចការពិសោធន៍របស់សិស្ស
- ការបង្ហាញលទ្ធផលពិសោធន៍
- ភ្លើងដែលចេញពីចង្ក្រានជារំភាយស្មើ
- បន្ទះលោហៈឡើងពណ៌ក្រហមជាការចម្លងកម្តៅ
- ផ្សែងធូបធ្វើចលនាចុះឡើងជាចលនាវិលវល់ ។

**ង- សំណួរពិភាក្សា**

តើការផ្ទេរកម្តៅកើតឡើងយ៉ាងដូចម្តេច?

**ច- សន្និដ្ឋាន**

..............................................................................................................................

..............................................................................................................................

..............................................................................................................................

..............................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

តើបញ្ញត្តិនៃបាតុភូតនៃការបន្ទេរកម្តៅដែលកើតមានឡើងក្នុងធម្មជាតិនេះ អាចយកមកបម្រើក្នុងការអនុវត្តក្នុងជីវភាពប្រចាំថ្ងៃដូចម្តេច?

## II. ផ្នែកទី២ ពិសោធន៍ថ្នាក់ទី១១
## ប្រធានបទទី១៖ ចរន្តខ្យល់ និងការសោត់នៃទ្វីប
## ថ្នាក់ទី១១ ជំពូក១ មេរៀនទី៤

**១.១- សេចក្តីណែនាំសម្រាប់គ្រូ**

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍ន៍នៅមុនពេលបង្រៀនពិសោធន៍ន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

**១.២- ឧបករណ៍** Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក១ ភពផែនដី មេរៀនទី៤ ផ្លាកតិចតូនិច ទំព័រ២៤ បានរៀនរួចហើយ<br>**ប្រធានបទ៖ ចរន្តវង្វល់ និងការសោត់នៃទ្វីប**<br>សម្ភារៈបានរៀបចំរួចរាល់រួមមាន ស្រោមដៃ | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| ការពារ កម្តៅ ចង្ក្រានហ្គាស ថាសទ្រវែងធ្វើពីអាលុយមីញ៉ូម ល័ក្ខពណ៌ សីតុណ្ហមាត្រ ទឹកត្រជាក់ ខ្មៅដៃ តែ និងកែវបេស៊ែ<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីចរន្តវង្វល់ និងការរសាត់នៃទ្វីប ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីចរន្តវង្វល់ និងការរសាត់នៃទ្វីប<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់(ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានរកសម្ភារៈគ្រប់គ្រាន់<br>□ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (**ចរន្តវង្វល់ និងការរសាត់នៃទ្វីប**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ។<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឬឆ្លើយសំណួរផ្ទាល់មាត់ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

| | |
|---|---|
| □ ឬធ្វើបទបង្ហាញជាក្រុម។ | |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

អ្នកវិទ្យាសាស្ត្រជនជាតិអាឡឺម៉ង់ម្នាក់ឈ្មោះ អាល់ព្រើដ វ៉េសេនី (Alfred Wegener) បានបង្កើត សម្មតិកម្មថា ទ្វីបធ្វើចលនា។ គំនិតអំពីការរសាត់នៃទ្វីបឃើតៗ នៅលើមណ្ឌលខាប់ត្រូវបានគេស្គាល់ថាជា ទ្រឹស្តីទ្វីបរសាត់។ ដោយយោងទៅលើទ្រឹស្តីទ្វីបរសាត់ និងទ្រឹស្តីគម្លាតបាតសមុទ្របានបញ្ជាក់ថា ទ្វីបធ្វើចលនា។ ដូចនេះទើបមានទ្រឹស្តីថ្មីមួយទៀតបានបង្កើតឡើងដើម្បីពន្យល់ទាំងទ្វីបរសាត់ និងគម្លាតបាតសមុទ្រគឺ ទ្រឹស្តីផ្លាកតិចតូនិច។ ទ្រឹស្តីនេះពន្យល់ថាមណ្ឌលថ្មរបស់ផែនដីបានប្រេះបែកជាផ្លាកតិចតូនិចយ៉ាងច្រើន និងធ្វើចលនាពីលើមណ្ឌលខាប់។ បរិមាណថាមពលដ៏ខ្លាំងដែលមិនគួរឱ្យជឿនោះ បានធ្វើឱ្យវត្ថុធំ ដូចជាផ្លាកតិចតូនិចមានចលនា។ អ្នកវិទ្យាសាស្ត្រកឃើញចម្លើយបានខ្លះៗថាមានកម្លាំងបីប្រភេទដូចជា កម្លាំងទ្រនុងរុញ កម្លាំងទំនាញនៃមណ្ឌលថ្ម និងកម្លាំងវង្វល់ ដែលធ្វើឱ្យផ្លាកមានចលនា។

### ខ- វត្ថុបំណង

- បង្ហាញពិសោធន៍គំរូនៃចរន្តវង្វល់ក្នុងផែនដីដែលធ្វើឱ្យផ្លាកតិចតូនិចមានចលនា។

### គ- វិធីសាស្ត្រ

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាគម្រោងបែបមូលដ្ឋាន។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| | | | | |
|---|---|---|---|---|
|  |  |  |  |  |
| ស្រោមដៃការពារកម្តៅ | ចង្ក្រានហ្គាស | ថាសទ្រវែងធ្វើពីអាលុយមីញ៉ូម | ល័ក្ខពណ៌ | សីតុណ្ហមាត្រ |
|  |  |  |  | |
| ទឹកត្រជាក់ | ខ្មៅដៃ | តែ | កែវបេស៊ែ | |

#### គ.២- ដំណើរការពិសោធន៍

- ដាក់កែវបេស៊ែនៅលើចង្ក្រានហ្គាស
- ចាក់ទឹកចូលក្នុងកែវបេស៊ែចំនួន៧០០ml
- វាស់សីតុណ្ហភាពទឹកដោយប្រើសីតុណ្ហមាត្រ
- ដាក់បន្ទះឈើចំនួន២កំណាត់ចូលក្នុងទឹកឱ្យនៅជិតគ្នា

- បន្ទាប់មកបញ្ឆេះភ្លើងចង្ក្រាន
- នៅពេលទឹកពុះខ្លាំង បន្ទះឈើចាប់ផ្តើមធ្វើចលនា
- ចាក់ល័ក្តពណ៌ និងតែចូលក្នុងទឹក
- ពាក់ស្រោមដៃហើយវាស់សីតុណ្ហភាពទឹក
- ចូរសង្កេត តើមានអ្វីកើតឡើងចំពោះបន្ទះឈើទាំងពីរ ល័ក្តពណ៌ និងតែ?
- សូមពន្លត់ភ្លើងចង្ក្រាន បន្ទាប់ពីចប់ដំណើរការ។

**ឃ- វិភាគលទ្ធផល**

- បង្ហាញលទ្ធផលពិសោធន៍
- បង្ហាញពីចលនារបស់ទឹក និងបន្ទះឈើតូចៗ។

**ង- សំណួរពិភាក្សា**

ក- ដោយផ្អែកលើការសង្កេតចលនារបស់ល័ក្ខពណ៌ និងស្លឹកតែ តើសីតុណ្ហភាព និងចលនារបស់ទឹកត្រឹមត្រូវដែរឬទេ?

ខ- តើចលនាបន្ទះឈើតូចៗទាំងពីរមានទំនាក់ទំនងយ៉ាងដូចម្តេចជាមួយនឹងចលនាទឹក?

គ- តើគំរូនេះមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេចជាមួយនឹងផ្លាកតិចតូនិច និងចលនារបស់ទ្វីប?

**ច- សន្និដ្ឋាន**

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- តើការសិក្សាពីចរន្តរង្វល់ និងការរសាត់នៃទ្វីបបានផ្តល់ចំណេះដឹងអ្វីខ្លះដល់ប្អូនៗ?

# ប្រធានបទទី២៖ របាយទឹកលើផែនដី
# ថ្នាក់ទី១១ ជំពូក២ មេរៀនទី១

## ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវង្វាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី១ វដ្តទឹក ទំព័រ៦២ បានរៀនរួចហើយ<br>**ប្រធានបទ៖ របាយទឹកលើកពផែនដី** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br><br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| □ សម្ភារៈបានរៀបចំរួចរាល់រួមមាន កែវបេស៊ែ ឬ កែវជ័រចំណុះ២៥០ml ចំនួន៤ កែវបេស៊ែ ចំណុះ១០០០mlចំនួន២ ស៊ីរ៉ាំងចំណុះ ៣០ml ចំនួន១ ក្រដាស ប៊ិក ហ្វឺត សម្រាប់ គណនា<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីរបាយទឹក លើភពផែនដី ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីរបាយទឹកលើភពផែនដី<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្ស រួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទី សមាជិកក្រុមម្នាក់ៗច្បាស់លាស់(ពី៤នាក់ទៅ ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែក ឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទី សមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបាន បែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការ ពិភាក្សារបស់សិស្សតាមក្រុម<br>✓ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និង សន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញ លទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (**របាយទឹកលើភពផែនដី**) ឱ្យ សិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ ពួកគេ<br>□ ការវាយតម្លៃៈ គ្រូអាចឱ្យសិស្ស<br>  □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ **កិច្ចការវាយតម្លៃៈ**<br>  □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>  □ ឆ្លើយសំណួរផ្ទាល់មាត់ |

| | |
|---|---|
| ☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម។ | ☐ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

នៅលើភពផែនដីមានផ្ទៃទឹកប្រមាណជា៧០% និងដីគោកចំនួន៣០%។ ទឹកនៅលើភពផែនដីភាគច្រើនគឺជាទឹកប្រៃស្ថិតក្នុងមហាសមុទ្រ មានរហូតដល់ទៅប្រមាណជា៩៧% ហើយមានតែ៣%ប៉ុណ្ណោះគឺជាទឹកសាប។ ទឹកសាប៣% នោះគឺមានប្រហែល ៣ភាគ៤ ជាផ្ទាំងទឹកកកដ៏ធំដែលនៅជិតប៉ូលខាងជើង និងប៉ូលខាងត្បូង។ ស្មើរតែ១ភាគ៤ នៃទឹកសាបគឺជាទឹកកកក្នុងដី។

### ខ- វត្ថុបំណង

- រៀបរាប់ពីបរិមាណទឹកលើភពផែនដីបានត្រឹមត្រូវតាមរយៈខ្លឹមសារមេរៀន
- អនុវត្តការញែកបរិមាណទឹកនៅលើភពផែនដី
- សិស្សមានស្មារតីចូលរួមថែរក្សា និងប្រើប្រាស់ទឹកប្រកបដោយភាពសន្សំសំចៃ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមបែបវិធីវិទ្យាសាស្ត្រ។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | កែវបេស៊ែ ឬកែវជ័រចំណុះ២៥០ml ចំនួន៤ |   |
| ២ | កែវបេស៊ែចំណុះ១០០០ml ចំនួន២ |  |
| ៣ | ស៊ីរ៉ាំងចំណុះ៣០ml ចំនួន១ |  |
| ៤ | ក្រដាស ប៊ិក ហ្វឺត សម្រាប់គណនា | |

### គ.២- ដំណើរការពិសោធន៍

**ជំហានទី១៖ សិស្សធ្វើការគណនារកបរិមាណទឹកនីមួយៗ**

- យើងឧទាហរណ៍បរិមាណទឹកចំនួន១០០០ml តំណាងឱ្យទឹកសរុបនៅលើភពផែនដី
- យើងដឹងថា នៅលើភពផែនដីមានបរិមាណទឹកប្រៃប្រមាណជា៩៧% និងទឹកសាប៣%
- ដូចនេះ យើងប្រើរូបមន្តសមាមាត្រ៖ ១០០០ml = ១០០%

X = ៣%

===> X =១០០០*៣/១០០=៣០ml

យើងបាន បរិមាណទឹកសាប ៣០ml ក្នុងចំណោមបរិមាណទឹកតំណាងឱ្យភពផែនដីសរុបចំនួន១០០០ml ដូច្នេះបរិមាណទឹកប្រៃមានចំនួន ៩៧០ml

- បន្ទាប់មក ឱ្យសិស្សធ្វើការគណនាបន្ត ដើម្បីរកបរិមាណទឹកលើដី ក្នុងដី និងទឹកកកតំបន់ប៉ូលក្នុងចំណោមបរិមាណទឹកចំនួន ៣០ml

យើងមាន ទឹកលើដីប្រមានជាមាន ០.៣% ទឹកក្នុងដីមាន ៣១% និងទឹកកកតំបន់ប៉ូល ៦៨.៧%

យើងបាន ទឹកលើដី = ៣០*០.៣/១០០=០.០៩ml

ទឹកក្នុងដី = ៣០*០៣១/១០០=៩.៣ml

ទឹកទឹកកកតំបន់ប៉ូល = ៣០*៦៨.៧/១០០=២០.៦១ml ។

**ជំហានទី២៖ សិស្សអនុវត្តការបូមបរិមាណទឹកទៅតាមក្រុមទឹកនីមួយៗ ដែលបានគណនាឃើញ**

- យើងប្រើកែវបេស៊ែចំណុះ១០០០ml មកដាក់ទឹកចំណុះ ១០០០ml
- កែវបេស៊ែរ ឬកែវជ័រចំនួន៤ផ្សេងទៀត យើងត្រូវសរសេរលើកែវទី១ គឺជាទឹកសាប កែវទី២ គឺជាទឹកលើដី កែវទី៣គឺជាទឹកក្នុងដី និងកែវទី៤គឺជាទឹកកកតំបន់ប៉ូល
- បន្ទាប់មក ឱ្យសិស្សមកបូមទឹកទៅតាមបរិមាណនីមួយៗ ដែលបានគណនាឃើញ។

### ឃ- លទ្ធផល

- ឱ្យសិស្សបង្ហាញលទ្ធផលពិសោធន៍
- គ្រូត្រូវសម្របសម្រួលលទ្ធផល ដែលបានរកឃើញដោយធ្វើការប្រៀបធៀបលទ្ធផលដែលបានរកឃើញថាតើបរិមាណទឹកប្រៃ និងទឹកសាប(លើដី ក្នុងដី និងទឹកកកតំបន់ប៉ូល)មានបរិមាណខុសគ្នាបែបណាខ្លះ?

### ខ- សំណួរពិភាក្សា

ក- តើក្រុមទឹកណាខ្លះដែលយើងអាចប្រើប្រាស់បាន និងប្រើប្រាស់មិនបាន? ហេតុអ្វី?

ខ- តើទឹកមានសារៈសំខាន់អ្វីខ្លះសម្រាប់ទ្រទ្រង់ជីវិតនៅលើភពផែនដី?

## ច- សន្និដ្ឋាន

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- តើមនុស្សយើងប្រើប្រាស់ទឹកសម្រាប់ធ្វើអ្វីខ្លះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ?

២- តើយើងត្រូវធ្វើដូចម្តេចខ្លះដើម្បីប្រើប្រាស់ទឹកសន្សំសំចៃ?

# ប្រធានបទទី៣៖ ការវាស់កម្រិតកំណកអំបិលក្នុងប្រភេទទឹកផ្សេងៗ
## ថ្នាក់ទី ១១ ជំពូក២ មេរៀនទី៣

## ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី (២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** ( ☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី៣ មហាសមុទ្រ ទំព័រ៧៩ បានរៀនរួចហើយ | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| **ប្រធានបទ៖ ការវាស់កម្រិតកំណកអំបិលក្នុងប្រភេទទឹកផ្សេងៗ**<br>□ សម្ភារៈបានរៀបចំរួចរាល់រួមមាន ចង្ក្រានហ្គាស ចំនួន៣ ខ្ទះចំនួន៣ ជញ្ជីងឌីជីថលចំនួន១ ស្លាបព្រាចំនួន៣ កែវបេស៊ែចំនួន៣ ស្រោមដៃ<br>□ សុវត្ថិភាពចំនួន៣គូ កែវជ័រប្លាស្ទិកចំនួន៣ ទឹកក្បង(ទឹកផេះ)ចំណុះកន្លះលីត្រ ទឹកសមុទ្រ ចំណុះ កន្លះលីត្រ ទឹកធម្មតាចំណុះកន្លះលីត្រ ស្កុត ក្រដាស១ដុំ<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការវាស់កម្រិតកំណកអំបិលក្នុងទឹកពីប្រភេទផ្សេងៗ ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីការវាស់កម្រិតកំណកអំបិលក្នុងប្រភេទទឹកផ្សេងៗ<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់(ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានរកសម្ភារៈគ្រប់គ្រាន់<br>□ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>✓ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |

| | |
|---|---|
| | |
| **ក្រោយពិសោធន៍** ( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ ( **ការវាស់កម្រិតកំណកអំបិលក្នុងប្រភេទទឹកផ្សេងៗ** ) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br><br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

ទឹកសមុទ្រមានរសជាតិប្រៃហើយបានមកពីលំហូរទឹកពីគ្រប់ទិសទីដែលនាំយកសារធាតុរ៉ែផ្សេងៗនៅលើផ្ទៃផែនដី។ សារធាតុរ៉ែដែលធ្វើឱ្យទឹកសមុទ្រប្រៃគឺ សូដ្យូមក្លរួ ( NaCl )។ ជាតិប្រៃនៅក្នុងប្រភពទឹកផ្សេងៗមានកម្រិតខុសៗគ្នា សូម្បីតែទឹកសមុទ្រនៅទីតាំងផ្សេងគ្នាក៏មានជាតិប្រៃខុសគ្នាដែរ។

### ខ- វត្ថុបំណង

- ប្រៀបធៀបកម្រិតកំណកអំបិលក្នុងទឹកសមុទ្រ ទឹកក្បួង( ទឹកផេះ ) និងទឹកធម្មតា។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមបែបវិធីវិទ្យាសាស្ត្រ។

#### គ.១- សំណួរគន្លឹះ

- តើកម្រិតអំបិលក្នុងទឹកសមុទ្រ ទឹកក្បួង( ទឹកផេះ ) និងទឹកធម្មតាខុសគ្នាដូចម្តេចខ្លះ ?

#### គ.២- សម្មតិកម្ម

.....................................................................................................................

.....................................................................................................................

.....................................................................................................................

#### គ.៣- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | ចង្ក្រានហ្គាសចំនួន៣ |  |
| ២ | ខ្ទះ ចំនួន៣ |  |
| ៣ | ជញ្ជីងឌីជីថលចំនួន១ |  |
| ៤ | ស្លាបព្រាចំនួន៣ | |
| ៥ | កែវបេស៊ែចំនួន៣ |  |
| ៦ | ស្រោមដៃសុវត្ថិភាពចំនួន៣គូ | |
| ៧ | កែវជ័រប្លាស្ទិកចំនួន៣ | |
| ៨ | ទឹកក្បុង( ទឹកផេះ )ចំណុះកន្លះលីត្រ | |
| ៩ | ទឹកសមុទ្រចំណុះកន្លះលីត្រ | |
| ១០ | ទឹកធម្មតាចំណុះកន្លះលីត្រ | |
| ១១ | ស្កុតក្រដាស១ដុំ | |

### គ.៤- ដំណើរការពិសោធន៍

**ជំហានទី១៖ ការរៀបចំសម្ភារៈ**

- រៀបចង្ក្រានហ្គាសទាំង៣ ដោយបិទស្លាកសញ្ញាសម្គាល់ ខ្ទះទឹកធម្មតា ខ្ទះទឹកក្បុង ខ្ទះទឹកសមុទ្រ

- រៀបកែវបេស៊ែទាំង៣ ដោយបិទស្លាកសញ្ញាសម្គាល់ ទឹកក្បុង ទឹកសមុទ្រ ទឹកធម្មតា
- ចាក់ទឹកទាំង៣ប្រភេទចូលក្នុងខ្ទះផ្សេងៗគ្នាចំណុះកន្លះលីត្រ។

**ជំហានទី២៖ ពិសោធន៍**

- ពាក់ស្រោមដៃសុវត្ថិភាពដើម្បីការពាររលាកភ្លើង ឬកម្តៅ
- បញ្ឆេះចង្ក្រានហ្គាសទាំង៣ ដើម្បីកម្តៅទឹកឱ្យពុះហើយរង់ចាំរហូតដល់ទឹកទាំង ៣ប្រភេទហួតអស់
- នៅពេលទឹកហួតអស់ភ្លាម យើងត្រូវយកបាតខ្ទះទៅត្រាំនឹងទឹកត្រជាក់ ដើម្បីឱ្យកំណកអំបិលផ្ទាត់ឡើង(ហើបឡើង) ងាយស្រួលយើងកោសយកកំណកអំបិល
- កោសអំបិលដាក់ក្នុងកែវប្លាស្ទិក
- ថ្លឹងអំបិលដែលទទួលបានជាមួយជញ្ជីងឌីជីថល និងកត់ត្រាលទ្ធផលក្នុងតារាង។

**ឃ- លទ្ធផល**

ចូរបំពេញលទ្ធផលក្នុងតារាងខាងក្រោម៖

| ប្រភេទទឹក | ទឹកធម្មតា | ទឹកក្បុង( ទឹកផេះ ) | ទឹកសមុទ្រ |
|---|---|---|---|
| បរិមាណអំបិល(g) | | | |

**ង- សំណួរពិភាក្សា**

ក- ក្នុងចំណោមប្រភេទទឹកទាំង៣នេះ តើប្រភេទទឹកមួយណាមានកម្រិតអំបិលច្រើនជាងគេ ហើយមានបរិមាណអំបិលប៉ុន្មានក្រាម ?

ខ- មូលហេតុអ្វីបានជាកម្រិតអំបិលក្នុងទឹកទាំង ៣ប្រភេទនេះ មានភាពខុសគ្នា? ចូរបកស្រាយ ។

**ច- សន្និដ្ឋាន**

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- នៅលើពិភពលោក តើប្រទេសណាខ្លះដែលត្រូវហ៊ុមព័ទ្ធដោយសមុទ្រ និងមហាសមុទ្រច្រើនជាងគេបំផុត(រាប់ឈ្មោះឱ្យបាន៥)? តើគេអាចទាញយកអំបិលក្នុងបរិមាណប៉ុន្មានតោនពីទឹកសមុទ្រក្នុង១ឆ្នាំ?

២- នាពេលបច្ចុប្បន្ន ប្រទេសដែលខ្វះទឹកសាបប្រើប្រាស់នោះ តើគេប្រើបច្ចេកទេស និងមធ្យោបាយដូចម្តេចខ្លះ ដើម្បីបំប្លែងទឹកសមុទ្រមកជាទឹកសាបសម្រាប់ប្រើប្រាស់?

## ប្រធានបទទី៤៖ ការប្រែប្រួលសម្ពាធនិងសីតុណ្ហភាព
## ថ្នាក់ទី១១ ជំពូក៣ មេរៀនទី២

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវធ្វើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើ បទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍**(☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក១ នានាភាពនៃភាវៈរស់ មេរៀនទី១ ចំណែកថ្នាក់ និងដើមឈើមែកធាងពូជអម្បូរ ទំព័រ៨-១៣ បានរៀនរួចហើយ<br>**ប្រធានបទ៖ ការប្រែប្រួលសម្ពាធបរិយាកាសដោយសីតុណ្ហភាព** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| ☐ សម្ភារៈបានរៀបចំរួចរាល់រួមមាន ចង្ក្រានហ្គាស កំសៀវដាំទឹក ចានដែក ដបកែវ២ ប៉ោងៗ ១ចង់ សីតុណ្ហមាត្រ និងស្រោមដៃការពារកម្តៅ<br>☐ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីការប្រែប្រួលសម្ពាធបរិយាកាសដោយសីតុណ្ហភាព ហើយបានចែកឱ្យសិស្សរួចរាល់<br>☐ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>☐ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់( ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង )។ | ☐ បានរកសម្ភារៈគ្រប់គ្រាន់<br>☐ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>☐ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍**( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| ☐ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>☐ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>☐ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន )។ | ☐ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>☐ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>☐ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ។<br>☐ បោសសម្អាតបន្ទប់<br>☐ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍**( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| ☐ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>☐ បញ្ចាំងវីដេអូ (**ការប្រែប្រួលសម្ពាធបរិយាកាសដោយសីតុណ្ហភាព**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>☐ ការវាយតម្លៃៈ គ្រូអាចឱ្យសិស្ស<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឬឆ្លើយសំណួរផ្ទាល់មាត់<br>☐ ឬធ្វើបទបង្ហាញជាក្រុម។ | ☐ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>☐ **កិច្ចការវាយតម្លៃ៖**<br>☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>☐ ឆ្លើយសំណួរផ្ទាល់មាត់<br>☐ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

បរិយាកាសភពផែនដីផ្សំឡើងពីម៉ូលេគុលនៃឧស្ម័នជាច្រើនប្រភេទ។ ម៉ូលេគុលទាំងនោះបានធ្វើចលនាឡើងចុះជុំវិញផែនដីដោយសារការប្រែប្រួលសីតុណ្ហភាព ហើយធ្វើឱ្យសម្ពាធបរិយាកាសផែនដីប្រែប្រួលផងដែរ។ តើសម្ពាធបរិយាសជាអ្វី? សម្ពាធបរិយាកាសគឺជាកម្លាំងសង្កត់របស់ម៉ូលេគុលខ្យល់មកលើផ្ទៃនៃតំបន់មួយជាក់លាក់។ តើសម្ពាធបរិយាកាសមានទំនាក់ទំនងជាមួយនឹងសីតុណ្ហភាពយ៉ាងដូចម្តេច?

### ខ- វត្ថុបំណង

- បង្ហាញពីការប្រែប្រួលសម្ពាធបណ្តាលមកពីសីតុណ្ហភាព។

### គ- វិធីសាស្ត្រ

- វិធីសាស្ត្រពិសោធន៍តាមបែបវិធីវិទ្យាសាស្ត្រ។

### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| | | | |
|---|---|---|---|
|  ចង្ក្រានហ្គាស |  កំសៀវដាំទឹក |  ចានដែក |  ដបកែវ២ |
|  ប៉េាងៗ១ចង់ |  សីតុណ្ហមាត្រ |  ស្រោមដៃការពារកម្តៅ | |

### គ.២- ដំណើរការពិសោធន៍

**ជំហានទី១៖**

- យកកាំសៀវដែលមានទឹកស្រាប់ដាក់ដាំលើចង្ក្រានហ្គាសឱ្យឡើងក្តៅ រួចយកសីតុណ្ហមាត្រមកវាស់សីតុណ្ហភាពដបទី១ និងដបទី២
- ពេលទឹកចាប់ផ្តើមក្តៅ យកទៅចាក់ចូលដបទី១ ហើយចាក់ទឹកក្តៅចេញវិញ និងវាស់សីតុណ្ហភាពដបទាំងពីរម្តងទៀត
- យកប៉េាងៗមកភ្ជាប់ជាមួយមាត់ដបទាំងពីរ
- ពិនិត្យមើលប៉េាងប៉េាងនៅលើដបទាំងពីរ

**ជំហានទី២៖**

- កត់ត្រាទិន្នន័យនៃលទ្ធផលពិសោធន៍ចូលក្នុងសន្លឹកកិច្ចការ។

## ឃ- វិភាគលទ្ធផល

- បង្ហាញលទ្ធផលពិសោធន៍
- ដាក់ដបទាំង២ក្បែរគ្នា រួចសង្កេតពីបម្រែបម្រួលប៉ោងៗទាំង២។

## ខ- សំណួរពិភាក្សា

ក- តើមានអ្វីកើតឡើងចំពោះប៉ោងៗដែលនៅលើដបទាំងពីរ?

ខ- តើមូលហេតុអ្វីធ្វើឱ្យប៉ោងៗនៅលើដបទី១អាចរុលចូលក្នុងដបបាន?

## ច- សន្និដ្ឋាន

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- តើការសិក្សាពីការប្រែប្រួលសម្ពាធបរិយាកាសដោយសីតុណ្ហភាពបានផ្តល់ចំណេះដឹងអ្វីខ្លះដល់ប្អូនៗ?

# ប្រធានបទទី៥៖ រដ្ឋទាំង៤ នៅក្នុងតំបន់អាកាសធាតុត្រជាក់បង្គួរ
# ថ្នាក់ទី១១ ជំពូក៣ មេរៀនទី៧

## ១.១- សេចក្ដីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្ដីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ន៍ន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍ន៍ន៍នៅមុនពេលបង្រៀនពិសោធន៍ន៍ន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវធ្វើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី (២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ន៍ន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗធ្វើ បទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយកបៀបវង្វាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៣ មេរៀនទី៧ តំបន់អាកាជាតុ ទំព័រ ១៣៨ បានរៀនរួចហើយ<br>**ប្រធានបទ៖ រដ្ឋទាំង៤ នៅក្នុងតំបន់ត្រជាក់បង្គួរ** | ☐ បានអាន និងរៀនទ្រឹស្ដីមេរៀន<br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| សម្ភារៈបានរៀបចំរួចរាល់រួមមាន ឧបករណ៍គំរូដំណើរវិលជុំនៃព្រះចន្ទ ផែនដី និងព្រះអាទិត្យ កែវពង្រីក សន្លឹកកិច្ចការ ខ្មៅដៃ រូបភាពផែនដី និងអ័ក្សរបស់វា ផែនទីអាកាសធាតុពិភពលោក<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីរដូវទាំង៤ នៅក្នុងតំបន់ត្រជាក់បង្គួរ ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីរដូវទាំង៤ នៅក្នុងតំបន់ត្រជាក់បង្គួរ<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់(ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>✓ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (**រដូវទាំង៤ នៅក្នុងតំបន់ត្រជាក់បង្គួរ**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ **កិច្ចការវាយតម្លៃ៖** |

| | |
|---|---|
| □ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ | □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

គេចែកអាកាសធាតុជាច្រើនតំបន់ផ្សេងៗគ្នា អាស្រ័យលើសីតុណ្ហភាពជាមធ្យមនៃតំបន់នោះ។ តំបន់អាកាសធាតុធំៗ បានបែងចែកជាតំបន់អាកាសធាតុតូចៗ ហើយតំបន់អាកាសធាតុតូចៗទាំងនោះ ក៏បានបែងចែកជាតំបន់តូចៗជាបន្តទៅទៀតដែរ។ តំបន់អាកាសធាតុធំៗមាន៣គឺ អាកាសធាតុតំបន់ប៉ូល អាកាសធាតុតំបន់ត្រជាក់បង្គួរ និងអាកាសធាតុតំបន់ត្រូពិច។

### ខ- វត្ថុបំណង

- បង្ហាញពីមូលហេតុដែលបង្កើតឱ្យមានរដូវទាំង៤ នៅលើពិភពលោក។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមបែបវិធីវិទ្យាសាស្ត្រ។

#### គ.១- សំណួរគន្លឹះ

- តើរដូវនៅលើផែនដីកើតឡើងយ៉ាងដូចម្តេច?

#### គ.២- សម្មតិកម្ម

.................................................................................................................................

.................................................................................................................................

.................................................................................................................................

.................................................................................................................................

#### គ.៣- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | ឧបករណ៍គំរូដំណើរវិលជុំនៃព្រះចន្ទ ផែនដី និង ព្រះអាទិត្យ |  |

<table>
<tr><td>២</td><td>កែវពង្រីក</td><td></td></tr>
<tr><td>៣</td><td>សន្លឹកកិច្ចការ</td><td><br>តារាងលទ្ធផលពិសោធន៍<br><table><tr><th>កាលបរិច្ឆេទ</th><th>រដូវនៅអឌ្ឍគោលខាងជើង</th><th>រដូវនៅអឌ្ឍគោលខាងត្បូង</th></tr><tr><td></td><td></td><td></td></tr><tr><td></td><td></td><td></td></tr><tr><td></td><td></td><td></td></tr><tr><td></td><td></td><td></td></tr></table></td></tr>
<tr><td>៤</td><td>ខ្មៅដៃ</td><td></td></tr>
<tr><td>៥</td><td>រូបភាពផែនដី និងអ័ក្សរបស់វា</td><td></td></tr>
<tr><td>៦</td><td>ផែនទីអាកាសធាតុពិភពលោក</td><td></td></tr>
</table>

## គ.៤- ដំណើរការពិសោធន៍

**ជំហានទី១៖**

- យកឧបករណ៍ពិសោធន៍តាមក្រុមនីមួយៗ រួចចាប់ផ្តើមសង្កេត



- បើកភ្លើងព្រះអាទិត្យ រួចបង្វិលរូបគំរូភពផែនដីតាមទីតាំងរស្សានរដូវ សរទរដូវ សិសិររដូវ និង និទាឃរដូវដូចមានរូបភាពខាងក្រោមជាគំរូ



- រូបកពផែនដី និងអ័ក្សរបស់វាដែលត្រឹមត្រូវទៅតាមរដូវទាំង៤៖ វស្សានរដូវ សរទរដូវ សិសិររដូវ និងនិទាឃរដូវ




**ជំហានទី២៖**

- កត់ត្រាការសង្កេតអ័ក្សទ្រេត និងកត់ចំណាំពន្លឺដែលផែនដីទទួលបាននៅតាមទីតាំងនៃរដូវធំទាំង៤តាមរយៈរូបភាពគំរូ។

## ឃ- លទ្ធផលពិសោធន៍

ចូរបកស្រាយលទ្ធផលដែលទទួលបាន៖

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

..............................................................................................................

## ង- សំណួរពិភាក្សា

ក- តើប្រទេសកម្ពុជាមានរដូវប៉ុន្មាន ? អ្វីខ្លះ ? តើប្រទេសអាមេរិចមានរដូវប៉ុន្មាន ? អ្វីខ្លះ ?

ខ- ហេតុអ្វីបានជាប្រទេសនីមួយៗមានចំនួនរដូវខុសៗគ្នា ?

## ច- សន្និដ្ឋាន

....................................................................................................................................

....................................................................................................................................

....................................................................................................................................

....................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- ចំពោះប្រទេសដែលមានរដូវទាំង៤ តើវាបានផ្តល់នូវគុណសម្បត្តិ និងគុណវិបត្តិអ្វីខ្លះ ?

២- នៅប្រទេសកម្ពុជា ប្រាសាទអង្គរវត្តមានថ្ងៃរះពេលព្រឹកព្រលឹមចំពីលើកំពូលប្រាសាទ តើគេអាចមើលឃើញនៅថ្ងៃណា ខែណា ? តើវាស្ថិតនៅក្នុងរដូវណាមួយក្នុងចំណោមរដូវទាំង៤នោះ ហើយមានឈ្មោះអ្វី ?

# ប្រធានបទទី៦៖ ការកកើតពពក
## ថ្នាក់ទី១១ ជំពូក៣ មេរៀនទី៨

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវធ្វើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើ បទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៣ មេរៀនទី៨ ទឹកក្នុងបរិយាកាស ពពក និងកំណកអាកាស ទំព័រ១៤៦ បានរៀនរួចហើយ<br>**ប្រធានបទ៖ ការកកើតពពក** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| □ សម្ភារៈបានរៀបចំរួចរាល់រួមមាន ស្រោមដៃ កំសៀវ កែវថ្មថ្លា បន្ទះអាលុយមីញ៉ូម ទឹកកក ទឹក និងចង្ក្រានហ្គាស<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការកកើតពពក ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីដំណើរការកកើតពពក<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួច រាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់(ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានរកសម្ភារៈគ្រប់គ្រាន់<br>□ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម<br>□ ផ្តល់គំរូរបាយការណ៍ពិសោធន៍ទៅសិស្ស (មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់<br>□ អាន និងស្វែងយល់បន្ថែម។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ(**ការកកើតពពក**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

នៅក្នុងបរិយាកាសជាន់ទាប ទឹកមាននៅគ្រប់ទីកន្លែងក្នុងទម្រង់ជាឧស្ម័ន ឬចំហាយទឹក។ ម៉ូលេគុលរបស់វាធ្វើចលនាដោយសេរីជាមួយនឹងអាតូម និងម៉ូលេគុលដទៃទៀត។ ក្នុងទម្រង់រាវម៉ូលេគុលនៅជិតគ្នា ហើយប្រជ្រៀតគ្នា និងទង្គិចគ្នាទៅវិញទៅមកឥតឈប់ឈរ។ យើងអាចមើលឃើញចំហាយទឹកនៅពេលដែលម៉ូលេគុលជាច្រើនរួមចូលគ្នាបង្កើតបានជាគ្រាប់ពពក ឬគ្រាប់ទឹកកកតូចៗ។

តើពពកជាអ្វី? ពពកគឺជាតំណក់ទឹកតូចៗ ឬក្រាមទឹកកកតូចល្អិតរាប់លានគ្រាប់ផ្តុំគ្នា។ នៅក្នុងបរិយាកាសពេលខ្លះពពកហាក់ដូចជាបាល់សំឡី ខ្លះដូចក្នុងសក់ និងខ្លះទៀតដូចភួយពណ៌ប្រផេះដែលបាំងបាត់ព្រះអាទិត្យ។ បើគ្មានពពកទេវាអាចនឹងគ្មានភ្លៀង ព្រឹល ផ្គរ រន្ទះ ឬឥន្ទធនូឡើយ។ ពពកខ្លះស្ថិតនៅរយៈកម្ពស់ខ្ពស់ ខ្លះស្ទើរតែប៉ះនឹងផ្ទៃដី ហើយផ្លាស់ប្តូរទម្រង់ឥតឈប់ឈរ ជួនកាលក្រាស់ ស្តើង តូច ឬធំជាដើម។

### ខ- វត្ថុបំណង

- បង្ហាញពីរបៀបនៃការបង្កើតពពកតាមរយៈការពិសោធ។

### គ- វិធីសាស្រ្តពិសោធន៍

- វិធីសាស្រ្តពិសោធន៍តាមបែបវិធីវិទ្យាសាស្រ្ត។

#### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមានៈ

| ល.រ | សម្ភារៈ | រូបភាព |
|---|---|---|
| ១ | ស្រោមដៃ |  |
| ២ | កំសៀវ |  |
| ៣ | កែវថ្មថ្លា |  |
| ៤ | បន្ទះអាលុយមីញ៉ូម |  |

| | | |
|---|---|---|
| ៥ | ដុំទឹកកក |  |
| ៦ | ទឹក |  |
| ៧ | ចង្ក្រានហ្គាស |  |

**គ.២- ដំណើរការពិសោធន៍**

**ជំហានទី១៖** ដាក់ដាំទឹកឱ្យពុះរួចយកទៅចាក់ក្នុងកែវជ័រថ្លា បន្ទាប់មកធ្វើការគ្រលែងកែវដើម្បីឱ្យមានកម្ដៅគ្រប់គ្រាន់នៅផ្ទៃខាងក្នុងនៃកែវនោះ។ សូមធ្វើការគ្រលែងដោយប្រុងប្រយ័ត្ន និងធ្វើការពាក់ស្រោមដៃផងដែរ។

**ជំហានទី២៖** បន្ទាប់មកធ្វើការដាក់បន្ទះអាលុយមីញ៉ូមជាមួយនឹងដុំទឹកកកគ្របពីលើគម្របដបកែវយ៉ាងរហ័ស រួចរង់ចាំសង្កេតលទ្ធផលប្រហែល៥នាទីសិន។

**ឃ- លទ្ធផល**

- ឱ្យសិស្សបង្ហាញលទ្ធផលពិសោធន៍
- គ្រូត្រូវសម្របសម្រួលលទ្ធផល។

**ង- សំណួរពិភាក្សា**

ក- ចូរប្អូនប្រៀបធៀបលទ្ធផលដែលបានរកឃើញ ថាតើវាមានលក្ខណៈដូចគ្នា ប្រហាក់ប្រហែលគ្នា ឬមានភាពខុសគ្នាខ្លាំង?

ខ- តើក្រុមនោះរៀបចំឧបករណ៍នៃការកកើតពពកដូចម្ដេច?

គ- តំណាងក្រុមចែករំលែកការពិសោធរបស់ខ្លួនហើយពន្យល់ថា តើហេតុអ្វីពួកគេសម្រេចចិត្តរៀបបែបនោះ?

**ច- សន្និដ្ឋាន**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- តើកន្លែងណាខ្លះដែលពពកអាចកើតមានឡើងច្រើនជាងគេ? ហេតុអ្វី?

២- តើពពកបានដើរតួនាទីអ្វីខ្លះក្នុងជីវភាពរស់នៅប្រចាំថ្ងៃ?

៣- ចូរប្អូនៗបង្កើតពពកដោយខ្លួនឯងនៅតាមគេហដ្ឋានរៀងៗខ្លួន។

# III. ផ្នែកទី៣ ពិសោធន៍ថ្នាក់ទី១២

## ប្រធានបទទី១៖ ការធ្វើចំណែកថ្នាក់សិលា

## ថ្នាក់ទី១២ ជំពូក១ មេរៀនទី២

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក១ មេរៀនទី២ សិលា (ទំព័រ១៤-២៧) បានរៀនរួចហើយ | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| **ប្រធានបទ៖ ការធ្វើចំណែកថ្នាក់សិលា**<br>□ សម្ភារៈបានរៀបចំរួចរាល់រួមមានកែវពង្រីកក្រដាសជូត ទឹកខ្មេះ ញញួរ ស្រោមដៃ វ៉ែនតា កែវ សំណាកគំរូសិលាទាំង៧ប្រភេទ និងតារាងលក្ខណៈរបស់សិលាទាំងប្រាំពីរប្រភេទ<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីការធ្វើចំណាត់ថ្នាក់សិលា ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីការធ្វើចំណាត់ថ្នាក់សិលា<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទី សមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានរកសម្ភារៈគ្រប់គ្រាន់<br>□ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រាចូលក្នុងសន្លឹកកិច្ចការ<br>□ ផ្ទៀងផ្ទាត់លទ្ធផលជាមួយតារាងលក្ខណៈរបស់សិលាដើម្បីកំណត់ឈ្មោះរបស់សិលានីមួយៗ។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ អោយសិស្សធ្វើបទបង្ហាញលទ្ធផល<br>□ បញ្ចាំងវីដេអូ (**ការធ្វើចំណាត់ថ្នាក់សិលា**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ សម្របសម្រួលចម្លើយរបស់សិស្ស<br>□ ការវាយតម្លៃ៖ សួរសំណួរផ្ទាល់មាត់ទៅសិស្ស<br>□ ប្រមូលសន្លឹកកិច្ចការ។ | □ សិស្សធ្វើបទបង្ហាញតាមក្រុមនីមួយៗពីលទ្ធផលរបស់ខ្លួន<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ **កិច្ចការវាយតម្លៃ៖** ឆ្លើយសំណួរផ្ទាល់មាត់<br>□ ប្រគល់សន្លឹកកិច្ចការ។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

សិលា គឺល្បាយនៃរ៉ែមួយ ឬច្រើនប្រភេទ។ ជាធម្មតាគេចែកថ្នាក់សិលាជា៣ប្រភេទធំៗគឺ សិលាម៉ាក់ម៉ា សិលាកម្ទេចកំណ និងសិលាប្រែកំណើត។ សិលាម៉ាក់ម៉ាកើតឡើងនៅពេលម៉ាក់ម៉ាចុះត្រជាក់នៅក្នុង ផែនដី

(សិលាជ្រៀត) ឬកំអែភ្នំភ្លើងកករឹងនៅលើផ្ទៃផែនដី(សិលាភ្នំភ្លើង)។ សិលាកម្ទេចកំណកើតឡើងដោយសារកម្ទេចកំណចាក់បង្គរលើគ្នាក្លាយជាស្រទាប់សង្កត់លើគ្នាយ៉ាងណែន និងបង្ហាំជាប់គ្នាដោយពុំចាំបាច់មានកម្ដៅ និងសម្ពាធខ្ពស់ដូចសិលាពីរប្រភេទទៀត(សិលាម៉ាក់ម៉ា និងសិលាប្រែកំណើត)។ រីឯសិលាប្រែកំណើតគឺជាសិលាដែលផ្លាស់ប្ដូរទម្រង់វាយភាព ឬសមាសធាតុផ្សំដោយសារកម្ដៅ និងសម្ពាធខ្ពស់ជាងសិលាកម្ទេចកំណ។ តើគេអាចកំណត់ឈ្មោះ និងប្រភេទសិលាដោយរបៀបណា?

## ខ- វត្ថុបំណង

- ការកំណត់ឈ្មោះ និងប្រភេទគំរូសិលា។

## គ- វិធីសាស្ត្រពិសោធន៍

ដើម្បីកំណត់ឈ្មោះ និងប្រភេទសិលាបាន គេត្រូវវិភាគលក្ខណៈរូបរបស់សិលាដោយផ្ទាល់មានដូចជា ពណ៌ ទំរង់គ្រាម ទំហំគ្រាប់ រចនាសម្ព័ន្ធរបស់គ្រាប់ រ៉ែដែលមានក្នុងសិលា ភាពរឹង ការបែកប្រេះ ដង់ស៊ីតេ និងលក្ខណៈផ្សេងៗទៀត(ប្រតិកម្មជាមួយអាស៊ីត ឬទឹកខ្មេះ ភាពប្រៃ...)។

- វិធីសាស្ត្រពិសោធន៍តាមជំហាននៃវិធីវិទ្យាសាស្ត្រ។

### គ.១- សម្ភារៈពិសោធន៍

លោកគ្រូអ្នកគ្រូត្រូវត្រៀមសម្ភារៈមួយចំនួនមានដូចជា៖

- កែវពង្រីក ក្រដាសជូត ទឹកខ្មេះ ញញួរ ស្រោមដៃ វ៉ែនតាការពារការខ្ទាតថ្មចូលភ្នែក ម៉ាស កែវសម្រាប់ដាក់កម្ទេចសិលា (រូបទី១)
- សំណាកគំរូសិលាដែលមានទំហំប្រហាក់ប្រហែលគ្នារួមមាន៖ សិលាក្រៃ សិលាថ្មកំបោរ សិលាហាលីត សិលាបាសាល់ សិលាក្រានីត សិលាណាយស៍ និងសិលាថ្មកែវ (រូបទី២)



**រូបទី១៖** ស្រោមដៃ ម៉ាស់ កែវពង្រីក ទឹកខ្មេះ វ៉ែនតា ញញួរ ក្រដាស់ជូត និងកែវ


១


២


៣


៤


៥


៦


៧

**រូបទី២៖** សំណាកគំរូសិលាទាំង៧ប្រភេទ

## គ.២- ដំណើរការពិសោធន៍

**ជំហានទី១៖** បន្ទាប់ពីសិស្សចូលតាមក្រុមរួច លោកគ្រូអ្នកគ្រូត្រូវ

- បែងចែកសំណាកគំរូសិលាដែលមានបង់លេខខុសលំដាប់ពីឈ្មោះសិលាក្នុង**តារាងទី២** ទៅតាមក្រុមនីមួយៗ
- បន្ទាប់មកចែក**តារាងទី១**សម្រាប់ឱ្យសិស្សបំពេញពេលសង្កេតឬវិភាគ។

**ជំហានទី២៖**

- ត្រូវពន្យល់សិស្សពីលក្ខណៈរូបនីមួយៗដែលត្រូវសង្កេត និងប្រាប់ពីវិធីកត់ត្រាចំណុចនីមួយៗ ដូចមានបង្ហាញក្នុង**តារាងទី១**។

**ជំហានទី៣៖** បន្ទាប់ពីក្រុមនីមួយៗបានបញ្ចប់ការសង្កេតលើសំណាកគំរូសិលារបស់ខ្លួនរួចហើយ

- ត្រូវប្ដូរសំណាកគំរូនោះជាមួយក្រុមផ្សេងៗដែលបានសង្កេត និងកត់ត្រាចប់រួចរាល់
- យើងធ្វើបែបនេះដើម្បីអោយក្រុមទាំងអស់អាចសង្កេតបានសិលាច្រើនប្រភេទ ប្រសិនបើនៅមានពេលឱ្យក្រុមនីមួយៗសង្កេត និងកត់ត្រាសិលាទាំងប្រាំពីរប្រភេទ។

តារាងទី១៖ លក្ខណៈរូបរបស់សិលាដែលសិស្សត្រូវសង្កេត និងកត់ត្រាពេលពិសោធន៍

| លក្ខណៈរូប | សិលា១ | សិលា២ | សិលា៣ | សិលា៤ | សិលា៥ | សិលា៦ | សិលា៧ |
|---|---|---|---|---|---|---|---|
| ពណ៌ | | | | | | | |
| ទំរង់គ្រាប់ | | | | | | | |
| ទំហំគ្រាប់ | | | | | | | |
| រចនាសម្ព័ន្ធគ្រាប់ | | | | | | | |
| រ៉ែក្នុងសិលា | | | | | | | |
| ភាពរឹង | | | | | | | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ការប្រេះបែក | | | | | | | |
| ផ្សេងៗ (ប្រតិកម្ម ជាមួយអាស៊ីតឬ ទឹកខ្មេះ) | | | | | | | |
| ឈ្មោះសិលា | | | | | | | |
| ប្រភេទសិលា | | | | | | | |
| ក្រុមសិលា | | | | | | | |

តារាងទី២៖ លក្ខណៈរបស់សិលាទាំង៧ប្រភេទ

| No. | ឈ្មោះសិលា | ប្រភេទ | ក្រុម | សមាសធាតុផ្សំ | វាយភាព | របៀបកើត |
|---|---|---|---|---|---|---|
| ១ | សិលាក្រានីត (Granite) | សិលាម៉ាក់ម៉ា | សិលាជ្រៅ | សំបូរជាតុស៊ីលីកា ឬ ក្វាត (ច្រើនជាង ៦០%) បែអូទីត មីកា និង ផែលស្ប៉ា | គ្រាប់ធំ គ្រើម និងមានពណ៌ភ្លឺ ពណ៌សលាយខ្មៅ | ការកករឹងនៃម៉ាក់ម៉ាក្នុងដី ក្នុងតំបន់ភ្លុយតុង (Pluton) |
| ២ | សិលាបាសាល់ (Basalt) | សិលាម៉ាក់ម៉ា | សិលាភ្នំភ្លើង | សំបូរកាល់សិកផ្លាជីអូក្លាសផែលស្ប៉ា និងពីរ៉ុកស៊ីន ហើយក៏អាចមានអាប៉ាទីត ម៉ាញ៉េទីត និងរ៉ែអូលីវីនផងដែរ | គ្រាប់ល្អិត និងមានពណ៌ក្រម៉ៅ | ការកករឹងនៃកំអែភ្នំភ្លើង |
| ៣ | សិលាក្រែ (Sandstone) | សិលាកម្ទេចកំណ | សិលាក្លាស្ទិច | ផ្សំពីគ្រាប់ក្វាតលាយលំនឹង ផែលស្ប៉ា មីកា និងរ៉ែផ្សេងទៀតបង្ហាំភ្ជាប់គ្នាដោយសារស៊ីលីកា កាល់ស៊ីត ឬ ដែកអុកស៊ីត | គ្រាប់មធ្យមចាប់ពីទំហំ 0.06 mm - 2 mm មានពណ៌លឿងឬក្រម៉ៅ | ការបង្ហាំគ្នានៃគ្រាប់ខ្សាច់នៅក្នុងសមុទ្រ ទឹកសាប ឬលើទ្វីប |

| No. | ឈ្មោះសិលា | ប្រភេទ | ក្រុម | សមាសធាតុផ្សំ | វាយភាព | របៀបកើត |
|---|---|---|---|---|---|---|
| ៤ | សិលាថ្មកំបោរសរីរាង្គ ( Organic Limestone ) | សិលាកម្ទេចកំណ | សិលាកម្ទេចកំណសរីរាង្គ | ផ្សំពីសារធាតុសរីរាង្គដូចជាខ្យងខ្ចៅ ឬផ្កាថ្ម និងកម្ទេចកំណផ្សេងទៀតដែលកប់នៅបាតសមុទ្រកាលពីរាប់លានឆ្នាំមុន | គ្រាប់មធ្យម ឬហ្មត់ មានពណ៌ប្រផេះ សិលានេះមានប្រតិកម្មជាមួយទឹកខ្មេះ ឬ អាស៊ីត | ការបង្ហាំភ្ជាប់គ្នានៃកម្ទេចកំណសរីរាង្គ |
| ៥ | សិលាហាលីត ( Halite) | សិលាកម្ទេចកំណ | សិលាកម្ទេចកំណគីមី | មានសមាសធាតុផ្សំពី NaCl ដូចគ្នានឹងអំបិលដែលកើតឡើងពីកំណក្រាមនៃសូលុយស្យុងរលាយក្នុងទឹកសមុទ្រ | មានក្រាមរាងគូប វាអាចមានច្រើនពណ៌ដូចជា ស គ្មានពណ៌ ទឹកក្រូច លឿង ក្រហម ខៀវ ផ្កាឈូក និងខ្មៅ | ហាលីតកើតពីការរំហួតនៃទឹកសមុទ្រ ឬបឹងទឹកប្រៃ |
| ៦ | សិលាថ្មកែវ ( Marble ) | សិលាប្រែកំណើត | គ្មានក្រាមបន្ទះ | សមាសធាតុផ្សំសម្បូរដោយរ៉ែកាល់ស៊ីតនិងមានរ៉ែខ្លះទៀតជា Wollastonite, brucite, tremolite, serpentine, ឬ diopside | ថ្មកែវជាសិលាផុយងាយឆ្កូតដោយកាំ បិត។ គេអាចធ្វើតេស្តដឹងតាមរយៈការប្រើប្រាស់អាស៊ីតអ៊ីដ្រូក្លរិចខ្សោយ។ សិលានេះមានច្រើនព៌ណរួមមាន ពណ៌បៃតង ខៀវ ឬ ប្រផេះ | ថ្មកែវកើតពីលំនាំប្រែកំណើតនៃសិលាថ្មកំបោរ |

| No. | ឈ្មោះសិលា | ប្រភេទ | ក្រុម | សមាសធាតុផ្សំ | វាយភាព | របៀបកើត |
|---|---|---|---|---|---|---|
| ៧ | សិលាណាយស៍ (Gneiss) | សិលាប្រែកំណើត | មានក្រាមបន្ទះ | សម្បូរដោយរ៉ែផែលស្ប៉ាត និងក្វាត ហើយក៏មានបន្សំនៃរ៉ែ muscovite, biotite និង hornblendeផងដែរ | ជាប្រភេទសិលាមានក្រាមធំមានលក្ខណៈស្រទាប់អាចមើលឃើញច្បាស់ មានពណ៌សលាយខ្មៅស្រដៀងគ្នានឹងសិលាក្រានីត | សិលាណាយស៍កើតឡើងពីលំនាំប្រែកំណើតដោយប៉ះទង្គិចនៃសិលាមីម៉ាទីត (migmatite) និងក្រានីត |

## ឃ- លទ្ធផល

- ឱ្យសិស្សឡើងបង្ហាញនិងពន្យល់ពីលទ្ធផលដែលបានពីការវិភាគសង្កេតរបស់ពួកគេ រួចកំណត់ឈ្មោះ និងប្រភេទសិលា
- គ្រូត្រូវសម្របសម្រួលលទ្ធផល។

## ខ- សំណួរពិភាក្សា

ក- តើប្អូនអាចប្រាប់បានទេ ហេតុអ្វីបានជាសិលាថ្មកំបោរ ឬសិលាថ្មកែវមានប្រតិកម្មជាមួយអាស៊ីត?

ខ- ហេតុអ្វីបានជាសិលាក្រែមានរចនាសម្ព័ន្ធជាស្រទាប់ៗ?

គ- ហេតុអ្វីបានជាសិលាប្រែកំណើតមានសភាពរឹងខ្លាំង?

## ច- សន្និដ្ឋាន

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

តើសិលាទាំងអស់នេះ ត្រូវបានគេយកមកប្រើសម្រាប់ធ្វើអ្វីខ្លះក្នុងជីវភាពប្រចាំថ្ងៃ?

## ប្រធានបទទី២៖ ការកំណត់វាយតាពនៃដី
## ថ្នាក់ទី១២ ជំពូក១ មេរៀនទី៣

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវធ្វើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី (២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- □ ឆ្លើយសំណួរផ្ទាល់មាត់
- □ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| □ ជំពូក២ មេរៀនទី៣ ដំណើរពុកផុយ និងកំណកំណើតដី (ទំព័រ២៨-៣៥) បានរៀនរួចហើយ<br>**ប្រធានបទ៖ ការកំណត់វាយភាពនៃដី** | □ បានអាន និងរៀនទ្រឹស្តីមេរៀន<br><br>□ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| □ សម្ភារៈបានរៀបចំរួចរាល់រួមមានប្រភេទដីតាមតំបន់ កំប៉ុង ឬកែវជ័រ ទឹក ចង្កឹះ ត្រីកោណវាយភាពដី តារាងទិន្នន័យនៃការគណនាលទ្ធផល បន្ទាត់ ម៉ាស៊ីនគិតលេខ ខ្មៅដៃ ប៊ិក ក្រដាស<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការពិសោធន៍វាយភាពនៃដី ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីដំណើរការពិសោធន៍វាយភាពនៃដី<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទី សមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ បញ្ចាំងវីដេអូ (**ការកំណត់វាយភាពនៃដី**) ឱ្យសិស្សសង្កេត និងយល់ពីរបៀបពិសោធន៍<br>□ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម។ | □ មើលវីដេអូ<br>□ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រាលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សបង្ហាញលទ្ធផលពិសោធន៍<br>□ ពិនិត្យ និងសម្របសម្រួលលទ្ធផលពិសោធន៍ដែលបានរកឃើញ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>  □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>  □ ឆ្លើយសំណួរផ្ទាល់មាត់<br>  □ ធ្វើបទបង្ហាញជាក្រុម<br>  □ លទ្ធផលផលិតបាន<br>□ ផ្តល់គំរូរបាយការណ៍ពិសោធទៅសិស្ស(មានមួយចប់ទាំងលទ្ធផល និងសន្និដ្ឋាន)<br>□ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ។ | □ សិស្សបង្ហាញលទ្ធផលរបស់ក្រុមខ្លួន<br>□ កិច្ចការវាយតម្លៃ៖<br>  □ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>  □ ឆ្លើយសំណួរផ្ទាល់មាត់<br>  □ ធ្វើបទបង្ហាញជាក្រុម<br>  □ លទ្ធផលផលិតបាន<br>□ ប្រគល់របាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

ដី គឺជាធនធានមូលដ្ឋានដែលទ្រទ្រង់ជីវិតនៅលើភពផែនដី។ វាគឺជាល្បាយនៃខ្យល់ ទឹក អំបិលខនិជ សារធាតុខនិជដែលបានមកពីសំណឹក និងការពុកផុយនៃសារពាង្គកាយផ្សេងៗ។ តួយ៉ាង នៅប្រទេសកម្ពុជាយើង គេបានបែងចែកដីជា៥ប្រភេទធំៗគឺ ដីសិលាក្រែលាយខ្សាច់ ដីក្រហម ឬដីសិលាបាសាល់ ដីខ្សាច់ ដីល្បាយដីឥដ្ឋ និងដីល្បាប់។ ដោយឡែក ចំពោះវាយភាពដីមាន៣ប្រភេទគឺ ដីខ្សាច់ ដីល្បាប់ និងដីឥដ្ឋ។ តាមរយៈប្រភេទ និងវាយភាពដីខាងលើនេះឃើញថា ប្រជាកសិករបានស្វែងរកដំណាំផ្សេងៗដែលត្រូវនឹងប្រភេទដីនីមួយៗ។

### ខ- វត្ថុបំណង

- បែងចែកប្រភេទដីដោយផ្អែកលើត្រីកោណវាយភាពដី
- បង្ហាញពីប្រភេទដំណាំដែលសាកសមទៅនឹងប្រភេទដីនីមួយៗ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាបែបគម្រោង។

#### គ.១-សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖




១- ប្រភេទដីតាមតំបន់




២- កំប៉ុង ឬកែវជ័រ



៣- ទឹក



៤- ចង្កឹះ




៥- បន្ទាត់




៦- ត្រីកោណវាយភាពដី



តារាងទិន្នន័យ និងគណនាលទ្ធផលការកំណត់វាយភាពដី

| គម្រូដី | កម្រាស់ដីសរុប | កម្រាស់ដីខ្សាច់ (cm) | កម្រាស់ដីល្បាប់ (cm) | កម្រាស់ដីឥដ្ឋ (cm) | %ដីខ្សាច់ | %ដីល្បាប់ | %ដីឥដ្ឋ | ប្រភេទដី |
|---|---|---|---|---|---|---|---|---|
| តំបន់ទី១ | | | | | | | | |
| តំបន់ទី២ | | | | | | | | |
| តំបន់ទី៣ | | | | | | | | |
| តំបន់ទី៤ | | | | | | | | |
| តំបន់ទី៥ | | | | | | | | |

៧- តារាងទិន្នន័យនៃការគណនាលទ្ធផល



៨- ម៉ាស៊ីនគិតលេខ



៩- ខ្មៅដៃ



១០- ប៊ិក



១១- ក្រដាស

## គ.២- ដំណើរការពិសោធន៍

### ជំហានទី១៖ ដាក់ដីចូលក្នុងកំប៉ុងនីមួយៗ

- យកសំណាកដីដែលប្រមូលបានពី៥តំបន់ផ្សេងៗគ្នាដាក់ចូលក្នុងកំប៉ុង។ ដីមួយប្រភេទត្រូវមានទម្ងន់ប្រហែល ២០០g (ដូចបង្ហាញក្នុងរូប)



- ចាក់ទឹកចូលទៅក្នុងកំប៉ុងទាំងអស់ រួចកូរឱ្យសព្វល្អ (ដូចបង្ហាញក្នុងរូប)



- ទុកពេលឱ្យរង ឬចាក់បង្គរជាស្រទាប់ៗ



**ជំហានទី២៖ ការវាស់កម្រាស់ដីដើម្បីគណនាលទ្ធផល**

- វាស់កម្រាស់ដីសរុប កម្រាស់វាយភាព(ដីឥដ្ឋ ដីល្បាប់ ដីខ្សាច់)នៃកំប៉ុងនីមួយៗ និងគណនាភាគរយវាយភាពដីតាមរូបមន្តៈ

$$\text{ភាគរយវាយភាពដី} = \frac{\text{កម្រាស់នៃវាយភាពដី}}{\text{កម្រាស់ដីសរុប}} \times 100$$




- រួចកត់លទ្ធផលចូលក្នុងតារាងខាងក្រោម៖

តារាងទិន្នន័យ និងលទ្ធផល

| ប្រភេទសំណាកដី | កម្រាស់ដីសរុប | កម្រាស់ដីខ្សាច់ | កម្រាស់ដីល្បាប់ | កម្រាស់ដីឥដ្ឋ | %ដីខ្សាច់ | %ដីល្បាប់ | %ដីឥដ្ឋ | ប្រភេទដី |
|---|---|---|---|---|---|---|---|---|
| តំបន់ទី១ | | | | | | | | |
| តំបន់ទី២ | | | | | | | | |
| តំបន់ទី៣ | | | | | | | | |
| តំបន់ទី៤ | | | | | | | | |
| តំបន់ទី៥ | | | | | | | | |

- បន្ទាប់ពីគណនាភាគរយកម្រាស់វាយភាពរួច ត្រូវយកទិន្នន័យនៃប្រភេទដីតាមតំបន់នីមួយៗមកគូស ក្នុងត្រីកោណវាយភាពដី (រូបខាងក្រោម)




និមិត្តសញ្ញា

→ ទិសដៅភាគរយដីល្បាប់ពី០%ទៅ១០០%

→ ទិសដៅភាគរយដីឥដ្ឋពី០%ទៅ១០០%

→ ទិសដៅភាគរយដីខ្សាច់ពី០%ទៅ១០០%

- បន្ទាប់មកយើងសរសេរលទ្ធផលចូលក្នុងតារាងខាងលើ ដូចឧទាហរណ៍ខាងក្រោម៖

| ប្រភេទសំណាកដី | កម្រាស់ដីសរុប | កម្រាស់ដីខ្សាច់ | កម្រាស់ដីល្បាប់ | កម្រាស់ដីឥដ្ឋ | %ដីខ្សាច់ | %ដីល្បាប់ | %ដីឥដ្ឋ | ប្រភេទដី |
|---|---|---|---|---|---|---|---|---|
| តំបន់ទី១ | ៦.៤ | ០.៨ | ៥ | ០.៦ | ១២.៥០ | ៧៨.១២ | ៩.៣៧ | ដីខ្សាច់មានដីជាតិ |
| តំបន់ទី២ | ៥.៦ | ៣.៥ | ១ | ១.១ | ៦២.៥០ | ១៧.៨៥ | ១៩.៦៤ | ដីឥដ្ឋ ខ្សាច់ មានដីជាតិ |
| តំបន់ទី៣ | ៥.៧ | ៤.៥ | ១ | ០.២ | ៧៨.៩៤ | ១៧.៥៤ | ៣.៥០ | ដីខ្សាច់មានដីជាតិ |
| តំបន់ទី៤ | ៥.២ | ១.៧ | ០.៦ | ២.៩ | ៣២.៦៩ | ១១.៥៣ | ៥៥.៧៦ | ដីឥដ្ឋ |
| តំបន់ទី៥ | ៦.៥ | ៤.២ | ១.៨ | ០.៥ | ៦៤.៦១ | ២៧.៦៩ | ៧.៦៩ | ដីខ្សាច់មានដីជាតិ |

**ឃ- លទ្ធផល**

- សិស្សបង្ហាញលទ្ធផលពិសោធន៍
- គ្រូត្រូវពិនិត្យ និងសម្របសម្រួលលទ្ធផលពិសោធន៍ដែលបានរកឃើញ ថាតើវាមាន លក្ខណៈដូចគ្នា ឬប្រហាក់ប្រហែលគ្នា ឬមានភាពខុសគ្នាខ្លាំង ?

**ង- សំណួរពិភាក្សា**

ក- តើដីណាដែលមានកម្រាស់វាយភាពដីខ្សាច់ក្រាស់ជាងគេ? តើដីនោះមានសភាពខុសពីដីផ្សេងដូចម្តេច? តើដីនោះយកមកពីតំបន់ណា?

ខ- តើដីណាដែលមានកម្រាស់វាយភាពដីឥដ្ឋក្រាស់ជាងគេ? តើដីនោះមានសភាពខុសពីដីផ្សេងដូចម្ដេច? តើដីនោះយកមកពីតំបន់ណា?

## ច- សន្និដ្ឋាន

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

..............................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- ចូររៀបរាប់ពីប្រភេទដីដែលសាកសមជាមួយប្រភេទដំណាំនីមួយៗ។

២- ហេតុអ្វីបានជាដីខ្លះមានខ្សាច់ច្រើន ហើយដីខ្លះមានដីឥដ្ឋច្រើន?

# ប្រធានបទទី៣ ៖ ការសង្កេតការប្រែប្រួលតារានិករតាមរដូវ
## ថ្នាក់ទី១២ ជំពូក២ មេរៀនទី១

### ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវធ្វើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើ បទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

### ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធ ន៍**( ☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី១ ភពផែនដី (ទំព័រ៤៦-៤៩) បានរៀនរួចហើយ<br>**ប្រធានបទ៖ សង្កេតការប្រែប្រួលតារានិករតាមរដូវ** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| □ សម្ភារៈបានរៀបចំរួចរាល់រួមមាន បាល់១ កូគោល១ ស្កុត១ កន្រ្តៃ១ កៅអី១២ សន្លឹកកាតឈ្មោះតារានិករទាំង ១២ និងផែនទីមេឃ( Zodiac )<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីការសង្កេតការប្រែប្រួលតារានិករតាមរដូវ ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីការសង្កេតការប្រែប្រួលតារានិករតាមរដូវ<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុម ម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានរកសម្ភារៈគ្រប់គ្រាន់<br><br>□ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br><br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា លទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ(ការសង្កេតការប្រែប្រួលតារានិករតាមរដូវ ) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br><br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

នៅពេលយប់ យើងសង្កេតឃើញតារានិករ៨៨ នៅលើមេឃ ។ តារានិករសំដៅទៅលើការប្រមូលផ្តុំនៃតារាដែលបង្កើតបានជារូបភាពផ្សេងៗដូចជា រូបសត្វ វត្ថុ ឬ រូបមនុស្ស ។ ជនជាតិក្រិចសម័យដើមសង្កេតមើលតារានិករចំនួន១២ ដែលតំណាងឱ្យតារានិករតាមរដូវ ឬប្រចាំខែ ហើយតារានិករទាំងអស់នេះគេអាចសង្កេតឃើញក្រោយព្រះអាទិត្យលិច។

តើយើងអាចសង្កេតមើលតារានិករទាំង១២ នេះយ៉ាងដូចម្តេច ?

### ខ- វត្ថុបំណង

- បង្ហាញពីរបៀបសង្កេតតារានិករតាមរដូវ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមវិធីវិទ្យាសាស្ត្រ។

### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមាន៖

| | | | |
|---|---|---|---|
|  បាល់ ១ |  ស្កុត១ |  កៅអី ១២ |  ប្រអប់ធំមួយ |
|  កន្ត្រៃ |  ភូគោល |  សន្លឹកកាតឈ្មោះតារានិករទាំង ១២ | |




ផែនទីមេឃ ( Zodiac )

## គ.២- ដំណើរការពិសោធន៍



**ជំហានទី១៖ ការរៀបចំសម្ភារៈ**

- រៀបចំតារានិករទាំង១២ តាមលំដាប់នៃក្រវាត់មេឃ
- រៀបចំប្លង់ដើម្បីដាក់ទីតាំងព្រះអាទិត្យ ទីតាំងផែនដី និងទីតាំងតារានិករទាំង ១២ដូចរូបខាងលើ។

**ជំហានទី២៖ ដំណើរការពិសោធន៍**

- រៀបចំកៅអីជារង្វង់ធំមួយដោយដាក់បែរខ្នងមករកចំណុចកណ្ដាល ហើយកៅអីទាំងនោះត្រូវស្ថិតនៅក្នុងគម្លាតស្មើគ្នា ដូចជាលេខរត់ក្នុងរង្វង់នាឡិកា

- សរសេរឈ្មោះតារានិករនីមួយៗនៃក្រវាត់មេឃលើកាត១២ ផ្សេងគ្នា
- ដាក់បាល់ក្នុងរង្វង់ ទុកលើប្រអប់ធំមួយដាក់ចំកណ្ដាល ដើម្បីឱ្យបាល់នេះស្ថិតនៅនឹងមួយកន្លែង
- ឈរខាងក្នុងរង្វង់កាន់កាតឈ្មោះតារានិករ និងស្ទុតរួចរំកិលខ្លួនផ្ទុយនឹងទ្រនិចនាឡិកាហើយបិទភ្ជាប់ឈ្មោះតារានិករដែលសរសេរលើកាតនៅកៅអីតាមលំដាប់លំដោយ ដូចតទៅ៖ ចៀមឈ្មោល គោឈ្មោល ត្រី អ្នករែកទឹក ពពែ ខ្ទាន់ធ្នូ ខ្យាដំរី ជញ្ជីងថាសពីរ ស្ត្រីព្រហ្មចារី សឹង្ហ ក្ដាម កូនភ្លោះ
- អ្នកតំណាងឱ្យផែនដីឈរនៅក្នុងរង្វង់កៅអី ។ ពេលដែលអ្នកធ្វើចលនាជុំវិញបាល់នោះមានន័យថាអ្នកបង្កើតគំរូរង្វិលជុំផែនដីវិលជុំវិញព្រះអាទិត្យ។ (សូមចំណាំថា មានតែផែនដីទេដែល ធ្វើចលនានៅចំពេលដែលយើងមើលឃើញព្រះអាទិត្យកំពុងមានចលនាក្នុងក្រវាត់មេឃ)
- ឈរពីមុខកាតតារានិករចៀមឈ្មោល សម្លឹងមើលទៅកាន់បាល់តំណាងឱ្យព្រះអាទិត្យ។បន្ទាប់មក សម្លឹងហួសទៅរកកៅអីម្ខាងទៀត ឆ្លងកាត់បាល់ផ្ទុយទីតាំងអ្នកឈរ (គូសនូវអ្វីដែលអ្នកបានឃើញ)
- រំកិលខ្លួនទៅកាន់កៅអីខាងស្ដាំដៃ (ចលនាផ្ទុយនឹងទ្រនិចនាឡិកា) សម្លឹងមើលដូចនៅទីតាំងមុន
- បន្តរំកិលខ្លួន និងធ្វើការសម្លឹងឱ្យបានរហូតដល់កៅអីចុងក្រោយ។ ធ្វើការសង្កេតទីតាំងព្រះអាទិត្យគ្រប់ទីតាំងកៅអីទាំងអស់ក្នុងរង្វង់ ។

ចូរបំពេញលទ្ធផលក្នុងតារាងខាងក្រោម៖

| ខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| តារា<br>និករ | ................<br>............... | ................<br>............... | ................<br>............... | ................<br>............... | ................<br>................ | ................<br>............... |

| ខែ | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|
| តារា<br>និករ | ................<br>............... | ................<br>............... | ................<br>............... | ................<br>............... | ................<br>................ | ................<br>................ |

**ឃ- លទ្ធផល**

- ឱ្យតំណាងក្រុមបង្ហាញលទ្ធផលពិសោធន៍
- គ្រូសម្របសម្រួលលទ្ធផលដែលទទួលបាន
- ឱ្យសិស្សសន្និដ្ឋានលទ្ធផល។

**ខ- សំណួរពិភាក្សា**

ក- តើព្រះអាទិត្យស្ថិតនៅក្នុងទីតាំងណានៃក្រវាត់មេឃ ?

ខ- នៅក្នុងខែមីនា តើប្អូននឹងមើលឃើញតារានិករអ្វី?

គ- នៅក្នុងខែកក្កដា តើប្អូននឹងមើលឃើញតារានិករអ្វី?

**ច- សន្និដ្ឋាន**

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

..................................................................................................................................

**ឆ- សំណួរពង្រីកចំណេះដឹង**

១- តើការសង្កេតតារានិករនៅពេលយប់អាចផ្តល់ព័ត៌មានអ្វីខ្លះដល់យើង?

# ប្រធានបទទី៤៖ បាតុភូតគ្រាស
# ថ្នាក់ទី១២ ជំពូក២ មេរៀនទី១

## ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង(២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី(១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី(២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើ បទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ

☐ ឆ្លើយសំណួរផ្ទាល់មាត់

☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក២ មេរៀនទី១ ភពផែនដី (ទំព័រ៥២-៥៣) បានរៀនរួចហើយ<br>**ប្រធានបទ៖ បាតុភូតគ្រាស** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន<br><br>☐ បានរកសម្ភារៈគ្រប់គ្រាន់ |

| | |
|---|---|
| □ សម្ភារៈបានរៀបចំរួចរាល់រួមមានគំរូប្រព័ន្ធព្រះអាទិត្យ ផែនដី និងព្រះចន្ទ<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីបាតុភូតគ្រាស ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីបាតុភូតគ្រាស<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់ | □ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ |
| □ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទីសមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។ | □ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រា ឬធ្វើបទបង្ហាញលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់។ |
| **ក្រោយពិសោធន៍** (☑ Check list) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (**បាតុភូតគ្រាស**) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ | □ សរសេររបាយការណ៍ ចូលសន្លឹកកិច្ចការ<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br><br>□ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

បាតុភូតគ្រាសគឺជាបាតុភូតដែលកើតឡើងនៅពេលដែលព្រះអាទិត្យ ព្រះចន្ទ និងផែនដីស្ថិតនៅលើបន្ទាត់តែមួយ ហើយស្រមោលនៃអង្គណាមួយចោលស្រមោលទៅលើអង្គមួយផ្សេងទៀត។ បាតុភូតគ្រាសមានពីរគឺ ចន្ទគ្រាស និងសូរ្យគ្រាស។

## ខ- វត្ថុបំណង

- បង្ហាញពីគំរូបាតុភូតចន្ទគ្រាស និងសូរ្យគ្រាសដោយប្រើប្រាស់ឧបករណ៍គំរូប្រព័ន្ធព្រះអាទិត្យដែលមាននៅក្នុងបន្ទប់ពិសោធន៍។

## គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមវិធីវិទ្យាសាស្ត្រ។

### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធមាន៖

- គំរូប្រព័ន្ធព្រះអាទិត្យ ផែនដី និងព្រះចន្ទ



### គ.២- ដំណាក់កាលពិសោធន៍

- យកឧបករណ៍គំរូប្រព័ន្ធព្រះអាទិត្យ ព្រះចន្ទ និងផែនដីដែលមាននៅក្នុងបន្ទប់ពិសោធន៍មកធ្វើការបង្ហាញពីទីតាំងរបស់ព្រះអាទិត្យ ព្រះចន្ទ និងផែនដីក្នុងពេលមានចន្ទគ្រាស និងសូរ្យគ្រាស
- បន្ទាប់មកបើកភ្លើងអំពូលរបស់ឧបករណ៍ រួចធ្វើការបង្វិលឱ្យផែនដី និងព្រះចន្ទធ្វើចលនា វិលជុំវិញព្រះអាទិត្យ
- ដំបូងបង្វិលបង្ហាញបាតុភូតចន្ទគ្រាសហើយសង្កេត និងកត់ត្រាទំនាក់ទំនងរវាងអង្គទាំងបី
- បន្ទាប់មកបង្វិលបង្ហាញបាតុភូតសូរ្យគ្រាស ហើយសង្កេត និងកត់ត្រាទំនាក់ទំនងរវាងអង្គទាំងបី។

## ឃ-លទ្ធផល

- អោយសិស្សពន្យល់បកស្រាយពីបាតុភូតចន្ទគ្រាស និងសូរ្យគ្រាស
- គ្រូត្រូវសម្របសម្រួលចម្លើយរបស់សិស្ស។

## ខ- សំណួរពិភាក្សា

ក- តើចន្ទគ្រាស និងសូរ្យគ្រាសមានលក្ខណៈខុសគ្នាដូចម្ដេច ?

ខ- តើទីតាំងរបស់ព្រះអាទិត្យ ព្រះចន្ទ និងផែនដីស្ថិតនៅដូចម្ដេចពេលមានបាតុភូតចន្ទគ្រាស និងសូរ្យគ្រាស ?

គ- ហេតុអ្វីបានជាចន្ទគ្រាស និងសូរ្យគ្រាសមិនកើតឡើងជារៀងរាល់ខែ ?

## ច- សន្និដ្ឋាន

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

......................................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- តើបាតុភូតចន្ទគ្រាស និងសូរ្យគ្រាសមានផលប្រយោជន៍ចំពោះមនុស្សយើងដែរឬទេ ?

២- តើបាតុភូតចន្ទគ្រាស និងសូរ្យគ្រាសផ្ដល់ផលវិបាកដល់មនុស្សយើងដែរឬទេ ?

# ប្រធានបទទី៥៖ កំណើនកម្តៅផែនដីដោយឧស្ម័នផ្ទះកញ្ចក់
# ថ្នាក់ទី១២ ជំពូក៤ មេរៀនទី៥

## ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី (២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- **ឧបករណ៍** Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធ** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៤ មេរៀនទី៥ កំណើនកម្តៅលើពិភពលោក ទំព័រ ១៦០ បានរៀនរួចហើយ | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

| | |
|---|---|
| **ប្រធានបទ៖ កំណើនកម្តៅផែនដីដោយឧស្ម័នផលផ្ទះកញ្ចក់**<br>□ សម្ភារៈបានរៀបចំរួចរាល់រួមមានប្រអប់កញ្ចក់ចំនួន២ ទែម៉ូម៉ែត្រចំនួន២ដើម ដបទឹក( ១,៥L)ចំនួន១ ទុយោប្រវែង៣៥cm ចំនួន១ កន្ត្រៃចំនួន១ ម្សៅមេនំប៉័ង ទឹកខ្មេះ នាឡិកាកំណត់ម៉ោង ឬទូរស័ព្ទ ក្រដាសមីលីម៉ែត្រប៊ិក អំពូលពងមាន់ ស្រោមដៃ និងម៉ាស<br>□ បានត្រៀម សន្លឹកកិច្ចការសិស្សអំពីពិសោធន៍កំណើនកម្តៅផែនដីដោយឧស្ម័នផលផ្ទះកញ្ចក់ ហើយបានចែកឱ្យសិស្សរួចរាល់។<br>□ បានត្រៀមវីដេអូអំពីកំណើនកម្តៅផែនដីដោយឧស្ម័នផលផ្ទះកញ្ចក់។<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទី សមាជិកក្រុមម្នាក់ៗច្បាស់លាស់ ( ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង )។ | □ បានរកសម្ភារៈគ្រប់គ្រាន់<br>□ បានអាន និងយល់ពីដំណើរការ ដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុម និងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។ |
| **ពេលធ្វើពិសោធន៍** ( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| □ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម។ | □ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងកត់ត្រាលទ្ធផល<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់។ |
| **ក្រោយពិសោធន៍** ( ☑ Check list ) | |
| **គ្រូ** | **សិស្ស** |
| □ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ | □ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់ដំណើរការ |

| | |
|---|---|
| □ បញ្ចាំងវីដេអូ (កំណើនកម្តៅផែនដីដោយឧស្ម័នផលផ្ទះកញ្ចក់) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ការពិសោធន៍របស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ | □ **កិច្ចការវាយតម្លៃ៖**<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម។ |

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្តីផ្តើម

ផលផ្ទះកញ្ចក់គឺជាបាតុភូតធម្មជាតិ ដែលបរិយាកាសចាប់យកថាមពលព្រះអាទិត្យ ដើម្បីរក្សាកម្តៅសម្រាប់ទ្រទ្រង់ជីវិតនៅលើផែនដី។ ឧស្ម័នផ្ទះកញ្ចក់មានដូចជា ចំហាយទឹក មេតាន ឧស្ម័នកាបូនិច អូសូន អាសូតអុកស៊ីត និងក្លរ៉ូភ្លុយអរ៉ូកាបូន។ ឧស្ម័នផ្ទះកញ្ចក់ដែលកើតដោយធម្មជាតិស្រូបយកកាំរស្មីក្រហម អាំងប្រា ដែលភាយចេញពីដី និងជួយរក្សាលំនឹងសីតុណ្ហភាពមធ្យមនៃផ្ទៃផែនដីឱ្យនៅត្រឹមតែ១៦$^{o}$C ដែលគាំទ្រជីវិតលើផែនដី។ ប៉ុន្តែ បើកំហាប់ឧស្ម័នផ្ទះកញ្ចក់កើនឡើង នោះវានឹងធ្វើឱ្យសីតុណ្ហភាពលើផែនដីកើនឡើងផងដែរ។

កំណើនផលផ្ទះកញ្ចក់នេះកើតឡើងដោយសារការអភិវឌ្ឍនៅទីក្រុង ការប្រើប្រាស់ប្រេងឥន្ធនៈ និងការប្រើប្រាស់សម្ភារៈប្លាស្ទិច។ ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅតែបន្ត នឹងនាំឱ្យកម្តៅលើពិភពលោកកើនឡើងប្រមាណពី ០.៣$^{o}$C ទៅ ០.៦$^{o}$C ក្នុងរយៈពេលមួយទសវត្សរ៍កន្លងទៅ។ ប្រសិនបើការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីសកម្មភាពមនុស្សនៅតែបន្តទៀត កំណើនកម្តៅលើពិភពលោកនឹងរឹតតែមានអត្រាខ្ពស់ថែមទៀត។ អ្នកវិទ្យាសាស្ត្រជាច្រើនបានបង្ហាញថា កំហាប់ឧស្ម័នផ្ទះកញ្ចក់បានកើនឡើងយ៉ាងច្រើននៅពេលមានកំណើនឧស្សាហកម្ម ការកាប់ឆ្ការព្រៃឈើយកដីសម្រាប់សង់លំនៅដ្ឋាន និងការធ្វើកសិកម្ម។ បច្ចុប្បន្ន គេសម្គាល់ឃើញថាមានកំហាប់ឧស្ម័នផ្ទះកញ្ចក់ពីរបែបបានកើនឡើងលើសកម្រិតដែលមិនធ្លាប់មានពីមុនមកគឺ កាបូនឌីអុកស៊ីត និងមេតាន។

### ខ- វត្ថុបំណង

□ បង្ហាញពីឧស្ម័នកាបូនិចជាឧស្ម័នផ្ទះកញ្ចក់ដែលធ្វើឱ្យផែនដីឡើងកម្តៅ។

### គ- វិធីសាស្ត្រពិសោធន៍

□ វិធីសាស្ត្រពិសោធន៍តាមបែបវិធីវិទ្យាសាស្ត្រ។

### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធមាន៖

| | | | |
|---|---|---|---|
|  |  |  |  |

| | | | |
|---|---|---|---|
| ១- ប្រអប់កញ្ចក់ចំនួន២ | ២- ទែម៉ូម៉ែត្រចំនួន២ ដើម | ៣- ដបទឹក(១,៥L) ចំនួន១ដប | ៤- ទុយោប្រវែង (៣៥cm) ចំនួន១ |
|  ៥- កន្ត្រៃចំនួន១ |  ៥- ម្សៅមេនំប៉័ង |  ៦- ទឹកខ្មេះ |  ៧- នាឡិកាកំណត់ម៉ោង ឬទូរស័ព្ទ |
|  ៨- ក្រដាសមីលីម៉ែត្រ |  ៩- ប៊ិក |  ១០- អំពូលពងមាន់ |  ១១- ស្រោមដៃ និង ម៉ាស |

## គ.២- ដំណើរការពិសោធន៍

- សរសេរលើប្រអប់កញ្ចក់មួយថា ឧស្ម័នធម្មតា និងប្រអប់កញ្ចក់មួយទៀតថា ឧស្ម័ន កាបូនិច
- យកទែម៉ូម៉ែត្រមកដាក់ក្នុងប្រអប់កញ្ចក់ឧស្ម័នធម្មតា១ដើម និងដាក់ក្នុងប្រអប់កញ្ចក់ឧស្ម័នកាបូនិច១ដើម
- យកដបទឹក (ចំណុះ១,៥L) សម្រាប់លាយសារធាតុបង្កើតឧស្ម័នកាបូនិច
- ចោះរន្ធលើគម្របដបរួចស៊កទុយោចូល
- យកទឹកខ្មេះចាក់ចូលក្នុងដបដែលបានត្រៀម រួចចាក់ម្សៅមេនំប៉័ងចូលដើម្បីបង្កើតឧស្ម័នកាបូនិច
- ដាក់ទុយោបញ្ចូលទៅក្នុងប្រអប់កញ្ចក់ឧស្ម័នកាបូនិច
- យកប្រអប់កញ្ចក់ទាំងពីរទៅហាលថ្ងៃ រួចកត់ត្រាបម្រែបម្រួលសីតុណ្ហភាព ៥នាទីម្តង រហូតគ្រប់៤ដង ដោយប្រើនាឡិកា ឬទូរស័ព្ទដើម្បីកំណត់ពេលវេលា
- យកទិន្នន័យមកគូសក្រាបលើក្រដាសមីលីម៉ែត្រ រួចធ្វើការប្រៀបធៀប
- ក្នុងករណីពុំមានពន្លឺព្រះអាទិត្យខ្លាំងដែលអាចឱ្យយើងធ្វើពិសោធន៍បាន យើងក៏អាចប្រើអំពូលស៊េរីស្តង់កម្លាំង១០០វ៉ាត់ជំនួសបានដែរ

- យើងត្រូវដាក់អំពូលឱ្យដល់បាតកញ្ចក់ឆ្ងាយពីទែម៉ូម៉ែត្របន្តិច
- បន្ទាប់មកយើងប្របាច់ឧស្ម័នកាបូនិចចូល រួចកត់ត្រាសីតុណ្ហភាពមុនពេលចាប់ផ្ដើមបើកភ្លើងអំពូល
- យើងត្រូវកត់ត្រាបម្រែបម្រួលសីតុណ្ហភាពរៀងរាល់១នាទីម្ដងឱ្យបាន៥ដង
- បន្ទាប់មកយកទិន្នន័យមកគូសនៅលើក្រដាសមីលីម៉ែត្រដែលអ័ក្សដេកជាចំនួននាទី និងអ័ក្សឈរជាសីតុណ្ហភាពដែលវាស់បាន(ដូចឧទាហរណ៍ក្នុងរូបខាងក្រោម) រួចធ្វើការប្រៀបធៀប។




## ឃ- លទ្ធផល

- ឱ្យសិស្សបង្ហាញលទ្ធផលពិសោធន៍
- គ្រូត្រូវសម្របសម្រួលលទ្ធផល។

## ង- សំណួរពិភាក្សា

ក- តើកម្ដៅនៅក្នុងប្រអប់ឧស្ម័នកាបូនិច និងប្រអប់ធម្មតា មួយណាខ្ពស់ជាងគេ?

ខ- ហេតុអ្វីបានជាឧស្ម័នកាបូនិចនៅលើផែនដីកើនឡើងច្រើនឡើង និងធ្វើឱ្យកម្ដៅនៅលើផែនដីក៏កើនឡើងដែរ?

## ច- សន្និដ្ឋាន

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

.....................................................................................................................

## ឆ- សំណួរពង្រីកចំណេះដឹង

១- តើធ្វើដូចម្ដេចដើម្បីកាត់បន្ថយកម្ដៅនៅលើភពផែនដី?

២- តើប្អូនៗគួរធ្វើអ្វីខ្លះ ដើម្បីជួយកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់?

៣- តើផលប៉ះពាល់នៃកំណើនកម្ដៅនៅលើពិភពលោកចំពោះជីវិតលើភពផែនដីមានអ្វីខ្លះ?ចូររៀបរាប់។

# ប្រធានបទទី៦៖ ការញែកសំណល់រឹង
## ថ្នាក់ទី១២ ជំពូក៤ មេរៀនទី៩

## ១.១- សេចក្តីណែនាំសម្រាប់គ្រូ

ដើម្បីឱ្យដំណើរការដឹកនាំមេរៀននេះប្រព្រឹត្តទៅប្រកបដោយភាពសកម្ម និងប្រសិទ្ធភាព លោកគ្រូ អ្នកគ្រូ ត្រូវអានសេចក្តីណែនាំខ្លីដូចខាងក្រោម៖

១- គ្រូអានឧបករណ៍ Check list ខាងក្រោមឱ្យបានយល់ច្បាស់

២- គ្រូរៀប ឬប្រមូលឧបករណ៍ និងសម្ភារៈបង្រៀនមួយចំនួនដូចជា៖ សម្ភារៈពិសោធន៍ សន្លឹកកិច្ចការសិស្ស កិច្ចតែងការបង្រៀន និងឧបករណ៍វាយតម្លៃឱ្យបានគ្រប់គ្រាន់

៣- គ្រូសាកល្បងអនុវត្តធ្វើពិសោធន៍នៅមុនពេលបង្រៀនពិសោធន៍ក្នុងថ្នាក់

៤- គ្រូអាចមានជម្រើសពីរសម្រាប់ថ្នាក់រៀននេះ (១)ជាថ្នាក់រៀនបែបសកម្មនៅក្នុងថ្នាក់ ឬក្រៅថ្នាក់ធម្មតា និង (២)ជាការសិក្សាបែបគម្រោង

៥- ក្នុងករណី (១)ថ្នាក់រៀនបែបសកម្មធម្មតា គ្រូត្រូវផ្ញើវីដេអូ និងសន្លឹកកិច្ចការសិស្សឱ្យសិស្សនៅមុនម៉ោងបង្រៀនមួយថ្ងៃយ៉ាងតិច (អនុវត្តបែបថ្នាក់រៀនត្រឡប់ Flipped classroom)

៦- ក្នុងករណី (២)ជាការសិក្សាបែបគម្រោង គ្រូត្រូវបែងចែកសិស្សជាក្រុម ហើយកំណត់ពីតួនាទី និងរយៈពេលឱ្យបានច្បាស់លាស់។ ចំពោះវីដេអូពិសោធន៍ ត្រូវបង្ហាញក្រោយពេលក្រុមនីមួយៗ ធ្វើបទបង្ហាញលទ្ធផលនៃការសិក្សាបែបគម្រោងរបស់ពួកគេ។

៧- ចំពោះកិច្ចការវាយតម្លៃ គ្រូអាចសម្រេចចិត្តជ្រើសយករបៀបវាយតម្លៃមួយក្នុងចំណោមខាងក្រោមនេះ

- ☐ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ
- ☐ ឆ្លើយសំណួរផ្ទាល់មាត់
- ☐ ធ្វើបទបង្ហាញជាក្រុម

៨- ចំពោះសំណួរពង្រីកចំណេះដឹង គ្រូអាចដាក់ជាកិច្ចការផ្ទះក៏បាន ប្រសិនបើពេលវេលាមិនគ្រប់គ្រាន់នៅក្នុងម៉ោងបង្រៀន។

## ១.២- ឧបករណ៍ Check List

គ្រូ និងសិស្សត្រូវត្រៀមតាមដំណាក់កាលទាំងបីគឺ មុនពិសោធន៍ កំឡុងពេលពិសោធន៍ និងក្រោយពិសោធន៍។

| **មុនពិសោធន៍** (☑ Check list) | |
|---|---|
| **គ្រូ** | **សិស្ស** |
| ☐ ជំពូក៤ មេរៀនទី៩ សំណល់ (ទំព័រ១៨៤)បានរៀនរួចហើយ<br>**ប្រធានបទ៖ ការញែកសំណល់រឹង** | ☐ បានអាន និងរៀនទ្រឹស្តីមេរៀន |

<table>
<tr><td>□ សម្ភារៈបានរៀបចំរួចរាល់រួមមានធុងប្រអប់កញ្ចក់ ស្រោមដៃ ដង្កៀប ហ្វឺតសរសេរលើក្រដាស ស្កុតបិត ក្រដាសA4 និងសំណល់រឹង១ធុង លាយចម្រុះគ្នា<br>□ បានត្រៀមសន្លឹកកិច្ចការសិស្សអំពីដំណើរការញែកសំណល់រឹង ហើយបានចែកឱ្យសិស្សរួចរាល់<br>□ បានត្រៀមវីដេអូអំពីដំណើរការញែកសំណល់រឹង<br>□ បានត្រៀមវិធី ឬសន្លឹកកិច្ចការវាយតម្លៃសិស្សរួចរាល់<br>□ បានបែងចែកក្រុមសិស្ស និងកំណត់តួនាទី សមាជិកក្រុមម្នាក់ៗច្បាស់លាស់ (ពី៤នាក់ទៅ៦នាក់/ក្រុម ឬប្រែប្រួលតាមភាពជាក់ស្តែង)។</td><td>□ បានរកសម្ភារៈគ្រប់គ្រាន់<br>□ បានអាន និងយល់ពីដំណើរការដែលគ្រូបានចែកឱ្យ<br>□ បានរៀបចំបង្កើតក្រុមនិងបែងចែកតួនាទីសមាជិកក្រុមបានច្បាស់លាស់។</td></tr>
<tr><td colspan="2">ពេលធ្វើពិសោធន៍ (☑ Check list)</td></tr>
<tr><td>គ្រូ</td><td>សិស្ស</td></tr>
<tr><td>□ ឱ្យសិស្សធ្វើសកម្មភាពតាមក្រុមដែលបានបែងចែករួចរាល់<br>□ សម្របសម្រួលតាមក្រុម<br>✓ បំផុសសិស្ស<br>✓ បង្កើនការប្រុងប្រយ័ត្ន<br>✓ សង្កេត តាមដានដំណើរការ និងការពិភាក្សារបស់សិស្សតាមក្រុម។</td><td>□ ប្រធានក្រុមដឹកនាំដំណើរការតាមក្រុមនីមួយៗ<br>□ សង្កេត ពិភាក្សា និងញែកសំណល់រឹង<br>□ សម្អាតសម្ភារៈ និងរៀបចំទុកដាក់ឱ្យបានរៀបរយ<br>□ បោសសម្អាតបន្ទប់។</td></tr>
<tr><td colspan="2">ក្រោយពិសោធន៍ (☑ Check list)</td></tr>
<tr><td>គ្រូ</td><td>សិស្ស</td></tr>
<tr><td>□ ប្រមូលរបាយការណ៍ ឬសន្លឹកកិច្ចការ<br>□ បញ្ចាំងវីដេអូ (ការញែកសំណល់រឹង) ឱ្យសិស្សសង្កេត និងផ្ទៀងផ្ទាត់ចម្លើយរបស់ពួកគេ<br>□ ការវាយតម្លៃ៖ គ្រូអាចឱ្យសិស្ស<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។</td><td>□ សរសេររបាយការណ៍ ឬសន្លឹកកិច្ចការពិសោធន៍<br>□ មើលវីដេអូ និងផ្ទៀងផ្ទាត់លទ្ធផល<br>□ កិច្ចការវាយតម្លៃ៖<br>□ ឆ្លើយសំណួរក្នុងសន្លឹកកិច្ចការ<br>□ ឆ្លើយសំណួរផ្ទាល់មាត់<br>□ ធ្វើបទបង្ហាញជាក្រុម<br>□ លទ្ធផលផលិតបាន។</td></tr>
</table>

## ១.៣- សន្លឹកកិច្ចការពិសោធន៍

### ក- សេចក្ដីផ្ដើម

ការគ្រប់គ្រងសំណល់ គឺជាបញ្ហាប្រឈមដ៏សំខាន់មួយនៅក្នុងសង្គមសម័យទំនើប ដែលតម្រូវឱ្យមានការយល់ដឹងច្បាស់លាស់អំពីប្រភេទសំណល់ផ្សេងៗគ្នា។ សំណល់កែច្នៃ និងសំណល់ប្រើប្រាស់ឡើងវិញ ដូចជា ក្រដាស ប្លាស្ទិច និងលោហៈ អាចត្រូវបានកែច្នៃជាផលិតផលថ្មីដែលជួយសន្សំសំចៃធនធានធម្មជាតិ។ សំណល់សរីរាង្គរួមមាន សំណល់អាហារ និងសំណល់រុក្ខជាតិ អាចត្រូវបានបំប្លែងទៅជាជីកំប៉ុស្តដ៏មានសារប្រយោជន៍។ សំណល់ពុលដូចជា ថ្នាំសម្លាប់សត្វល្អិត និងប្រេងម៉ាស៊ីន តម្រូវឱ្យមានការប្រុងប្រយ័ត្នក្នុងការគ្រប់គ្រងដើម្បីចៀសវាងការបំពុលបរិស្ថាន។ ចំណែកឯសំណល់គ្រោះថ្នាក់ដូចជា សំណល់វេជ្ជសាស្ត្រ និងសារធាតុគីមីឧស្សាហកម្ម ត្រូវការវិធានការពិសេសក្នុងការបោះចោលដើម្បីការពារសុខភាពសាធារណៈ។ ការយល់ដឹងអំពីប្រភេទសំណល់ទាំងនេះ និងការអនុវត្តវិធីសាស្ត្រគ្រប់គ្រងសមស្រប គឺមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន និងធានានិរន្តរភាពនាពេលអនាគតគ្រប់ជំនាន់។

### ខ- វត្ថុបំណង

- អនុវត្តការញែកសំណល់រឹងឱ្យបានត្រឹមត្រូវ។

### គ- វិធីសាស្ត្រពិសោធន៍

- វិធីសាស្ត្រពិសោធន៍តាមការសិក្សាគម្រោងបែបមូលដ្ឋាន។

### គ.១- សម្ភារៈពិសោធន៍

សម្ភារៈសម្រាប់ប្រើប្រាស់ក្នុងការពិសោធរួមមានៈ

- ធុងប្រអប់កញ្ចក់ ស្រោមដៃ ដង្កៀប ហ្វឺតសរសេរលើក្រដាស ស្កុតបិត ក្រដាសA4
- សំណល់រឹងមួយធុងរួមមាន ស្លឹកឈើ សំណល់ផ្ទះបាយ ក្រដាស ថង់ប្លាស្ទិក ចានជ័រ ទុយោ កំប៉ុងប្លាស្ទិច កែវកញ្ចក់ សម្បកថ្នាំពេទ្យ បង់រុំរបួស ស្រោមដៃ ថ្មពិល ថ្មទូរស័ព្ទ ម្ជុលចាក់ថ្នាំ និងអំពែងកែវជាដើម។



រូបភាពសម្ភារៈដែលត្រូវប្រើប្រាស់

## គ.២- ដំណើរការពិសោធន៍

- ចែកសិស្សជាក្រុមតូចៗ
- ប្រើហ្វឺតសរសេរស្លាកសម្គាល់ប្រភេទនៃសំណល់នៅលើក្រដាស A4 ថា សំណល់កែច្នៃ និងសំណល់ប្រើប្រាស់ឡើងវិញ សំណល់សរីរាង្គ សំណល់ពុល និងសំណល់គ្រោះថ្នាក់
- បិតស្លាកសម្គាល់លើប្រអប់កញ្ចក់ដោយប្រើស្កុត
- ចាក់សំណល់លើតុ
- ឱ្យសិស្សចាប់សំណល់ដាក់ធុងតាមប្រភេទនៃសំណល់នីមួយៗដោយប្រើដង្កៀប
- កត់ត្រាសំណល់តាមប្រភេទនីមួយៗក្នុងតារាងនៃសន្លឹកកិច្ចការខាងក្រោម៖

| សំណល់កែច្នៃ និងប្រើប្រាស់ឡើងវិញ | សំណល់សរីរាង្គ | សំណល់ពុល | សំណល់គ្រោះថ្នាក់ |
|---|---|---|---|
| | | | |

## ឃ- លទ្ធផល

- ឱ្យតំណាងក្រុមបង្ហាញលទ្ធផល
- គ្រូសម្របសម្រួលលទ្ធផលដែលសិស្សបកស្រាយ។

## ខ- សំណួរពិភាក្សា

ក- តើសំណល់អ្វីខ្លះដែលអាចដាក់ក្នុងធុងជីកំប៉ុស្ត ?

ខ- តើវត្ថុខាងក្រោមនេះ មួយណាដែលអាចកែច្នៃបានច្រើនដង ?

១- ក្រដាស

២- ប្លាស្ទិក

៣- កែវ

៤- អាលុយមីញ៉ូម

គ- តើការញែកសំណល់រឹងត្រូវធ្វើនៅពេលណា ?

១- នៅពេលប្រមូលសំរាម

២- នៅពេលទិញទំនិញ

៣- នៅពេលបោះចោល

៤- នៅកន្លែងចាក់សំរាម

ឃ- តើសំណល់ខាងក្រោមនេះ មួយណាដែលមិនអាចកែច្នៃបាន ?

១- កំប៉ុងអាលុយមីញ៉ូម

២- ដបកែវ

៣- ក្រដាសកាសែត

៤- ស្រោមអាហារប្រឡាក់ប្រេង

**ច- សន្និដ្ឋាន**

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

.......................................................................................................................................

**ឆ-សំណួរពង្រីកចំណេះដឹង**

១- តើការញែកសំណល់រឹងមានផលប្រយោជន៍អ្វីខ្លះដល់មនុស្ស និងដល់បរិស្ថាន ?

# សេចក្តីសន្និដ្ឋាន

សៀវភៅពិសោធន៍នេះបានបង្ហាញនូវដំណើរការដ៏សំខាន់មួយក្នុងការបង្រៀន និងរៀនវិទ្យាសាស្ត្រ សម្រាប់ថ្នាក់ទី១០ ទី១១ និងទី១២។ តាមរយៈការរួមបញ្ចូលគ្នានូវសេចក្តីណែនាំគ្រូ និងសន្លឹកកិច្ចការពិសោធន៍របស់សិស្ស សៀវភៅនេះបានបង្កើតនូវបរិយាកាសសិក្សាដែលមានលក្ខណៈអន្តរសកម្ម និងផ្តោតលើការស្រាវជ្រាវ។

សេចក្តីណែនាំក្នុងឧបករណ៍ Check List របស់គ្រូបានផ្តល់នូវក្របខណ្ឌដ៏រឹងមាំសម្រាប់ការអនុវត្តពិសោធន៍ប្រកបដោយប្រសិទ្ធភាព។ វាបានណែនាំគ្រូអំពីរបៀបរៀបចំ អនុវត្ត និងវាយតម្លៃសកម្មភាពនីមួយៗ។ ការណែនាំទាំងនេះក៏បានជួយធានាឱ្យមានសុវត្ថិភាព និងប្រសិទ្ធភាពក្នុងការប្រើប្រាស់សម្ភារៈ និងឧបករណ៍ផងដែរ។

សន្លឹកកិច្ចការ ពិសោធន៍របស់សិស្សបានផ្តល់នូវរចនាសម្ព័ន្ធសម្រាប់សិស្សក្នុងការកត់ត្រាការសង្កេត វិភាគទិន្នន័យ និងទាញសេចក្តីសន្និដ្ឋាន។ សន្លឹកកិច្ចការទាំងនេះមិនត្រឹមតែជាឧបករណ៍សិក្សាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាមធ្យោបាយដ៏មានប្រសិទ្ធភាពសម្រាប់គ្រូក្នុងការវាយតម្លៃការយល់ដឹង និងជំនាញរបស់សិស្សផងដែរ។

ប្រធានបទដែលត្រូវបានគ្របដណ្តប់ក្នុងសៀវភៅនេះ ចាប់ពីការកំណត់អត្តសញ្ញាណផូស៊ីលរហូតដល់ការសិក្សាអំពីឧស្ម័នផ្ទះកញ្ចក់ បានបង្ហាញពីវិសាលភាពទូលំទូលាយនៃចំណេះដឹងវិទ្យាសាស្ត្រ។ ពួកវាបានផ្សារភ្ជាប់ទ្រឹស្តីវិទ្យាសាស្ត្រទៅនឹងបញ្ហាពិត ដែលជួយឱ្យសិស្សមើលឃើញពីភាពពាក់ព័ន្ធនៃការសិក្សារបស់ពួកគេ។

ជាសរុប សៀវភៅណែនាំពិសោធន៍នេះបានផ្តល់នូវធនធានដ៏មានតម្លៃសម្រាប់គ្រូ និងសិស្ស។ វាបានលើកកម្ពស់វិធីសាស្ត្របង្រៀន និងរៀនដែលមានលក្ខណៈអន្តរសកម្ម និងផ្អែកលើការស្រាវជ្រាវ ដែលមិនគ្រាន់តែជួយឱ្យសិស្សយល់ដឹងអំពីគោលការណ៍វិទ្យាសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអភិវឌ្ឍជំនាញចាំបាច់សម្រាប់ការសិក្សាវិទ្យាសាស្ត្រនៅកម្រិតខ្ពស់ជាងនេះ និងអាជីពនាពេលអនាគតផងដែរ។

ចុងបញ្ចប់តាមរយៈសៀវភៅណែនាំនេះ យើងខ្ញុំសង្ឃឹមថាគ្រូនឹងមានទំនុកចិត្តក្នុងការអនុវត្តមេរៀនពិសោធន៍ប្រកបដោយប្រសិទ្ធភាព ហើយសិស្សនឹងមានការចាប់អារម្មណ៍ និងរីករាយក្នុងការស្វែងយល់អំពីពិភពវិទ្យាសាស្ត្រដ៏អស្ចារ្យនេះ។ ទោះបីជាយ៉ាងណាក៏ដោយ ការសិក្សាគឺជាដំណើរការមួយដែលបន្តជានិច្ច ហើយយើងលើកទឹកចិត្តឱ្យគ្រូ និងសិស្សបន្តស្វែងរកចំណេះដឹង និងឱកាសថ្មីៗ ក្នុងវិស័យវិទ្យាសាស្ត្រ។

**ឯកសារយោង**

- ណារ៉េត ប៉ូលីរីន និង សុក រិទ្ធី.(២០២៤).*ផែនដី និងបរិស្ថានវិទ្យាថ្នាក់ទី១០*. ភ្នំពេញ. គ្រឹះស្ថានបោះពុម្ពនិងចែកចាយ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ណារ៉េត ប៉ូលីរីន. នី សុពុទ្ធី. និង លីម កន្និដ្ឋា.(២០២៤).*ផែនដី និងបរិស្ថានវិទ្យាថ្នាក់ទី១១*. ភ្នំពេញ. គ្រឹះស្ថានបោះពុម្ពនិងចែកចាយ របស់ក្រសួងអប់រំ យុវជន និងកីឡា
- ណារ៉េត ប៉ូលីរីន. នី សុពុទ្ធី. និង លីម កន្និដ្ឋា.(២០២៤).*ផែនដី និងបរិស្ថានវិទ្យាថ្នាក់ទី១២*. ភ្នំពេញ. គ្រឹះស្ថានបោះពុម្ពនិងចែកចាយ របស់ក្រសួងអប់រំ យុវជន និងកីឡា